# ចម្ងាយភាព
# ស្ងៀមស្ងាត់

ការសម្តែងថ្មីរបស់កម្ពុជា

និពន្ធដោយ អាន់ម៉ារី ព្រីនស៍



# ទម្លាយភាព
# ស្ងៀមស្ងាត់

## ការសម្តែងថ្មីរបស់កម្ពុជា

និពន្ធដោយ អាន់ម៉ារី ព្រីនស៍

**ចូលរួមដោយ៖**

**នាយក/អ្នកនិពន្ធបទភ្លេង និងទំនុកច្រៀង៖**
អាន់ម៉ារី ព្រីនស៍ (ប្រទេសហូឡង់)

**កំណាព្យដោយ៖** អ៊ូ សំអឿ (អ៊ូ អឿ)
លើកលែងតែ៖ ទុក្ខសោករបស់ប្រជាជនកម្ពុជា និពន្ធដោយ សាធ ប៊ុនរិទ្ធ

**ជំនួយការនាយក/នាដសាស្ត្រ៖**
ជ័យ ច័ន្ទកិត្យា

**និពន្ធសាច់រឿងល្ខោន/ស្រាវជ្រាវ៖**
ណាន វ៉ាន់ ហួត (ប្រទេសហូឡង់)

**តួសម្តែង៖**
ម៉ម សុខលី
កូវ សុធារី
ធុន ស៊ីណា
ប៉ុក សុវណ្ណា
ណេន ភារិទ្ធ

**អ្នកច្រៀង៖**
ឃិន វុត្ថា

**អ្នករាំ៖**
ខៀវ សុវណ្ណារិទ្ធ

**អ្នកនិពន្ធបទភ្លេង/អ្នកលេងភ្លេងពីមុន៖**
ឡេង សកុណា

**អ្នកនិពន្ធបទភ្លេងបច្ចុប្បន្ន/អ្នកលេងភ្លេង៖**
រស់ សុគន្ធា

**អម្រឹតាសិល្បៈ (អ្នកផលិតល្ខោន)៖**
កង ឫទ្ធិសាល *នាយកប្រតិបត្តិ*
ហួត ប៊ុននី - *អ្នកសម្របសម្រួលផលិតកម្ម និងជាអ្នកគ្រប់គ្រងឆាក*
លឹម ច័ន្ទបូរ៉ាមី - *ហិរញ្ញឹក និងអ្នកសម្របសម្រួលរដ្ឋបាល*
ចេង បូរី - *ជំនួយការបច្ចេកទេស*
ដង ចរិយា - *ជំនួយការអ្នកគ្រប់គ្រងឆាក និងជាជំនួយការផលិតកម្ម*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**
ឆាំង យុ - *នាយកប្រតិបត្តិ*
ផេង ពង្សរ៉ាស៊ី - *នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា*
មីន សាណាស់ - *អ្នកស្រាវជ្រាវ*
ផាត សិលា - *អ្នកស្រាវជ្រាវ*

**គំនិតផ្តែប្រឌិត៖** ឆាំង យុ
**រៀបចំក្រាហ្វិច៖** លី សេនសូនីឡា (www.novacambodia.com)

**រូបថតទំព័រមុខ៖** អ៊ូច មករា
**រូបថតសខ្មៅ៖** បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

**ឧបត្ថម្ភដោយ៖** ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងសម្ព័ន្ធអន្តរជាតិនៃទីតាំងមនសិការ។

រក្សាសិទ្ធិ ២០១៨។

ស្នាដៃនេះគឺដើម្បីសងគុណដល់

# ម្តាយទាំងអស់

ដែលចិញ្ចឹមកូនរបស់ខ្លួនដោយបាតដៃទទេ, គ្មានស្បែកជើង, គ្មានការសិក្សា ហើយនិងដែលជាអ្នកកសាងប្រទេសឡើងវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។

# មាតិកា


| | | | |
|---|---|---|---|
| ១ | ការចាប់ផ្តើម | ២៣ | ឈុតទី ៦ |
| ៣ | ឈុតទី ១ | ២៧ | ឈុតទី ៧ |
| ៧ | ឈុតទី ២ | ៣៣ | ឈុតទី ៨ |
| ១១ | ឈុតទី ៣ | ៤០ | សេចក្តីបញ្ចប់ |
| ១៥ | ឈុតទី ៤ | ៤២ | ប្រវត្តិនៃល្ខោននិយាយ |
| ១៩ | ឈុតទី ៥ | ៤៥ | កម្មវិធីសម្រាប់ឆ្នាំ ២០១៩ |




ខាន់ មុយនិច ឈរនៅក្នុងវត្តរបស់ជីតាខ្លួនកាលវ័យកុមារ
វត្តសំរោងពន្លៃ (កសាងនៅដើមទសវត្សរ៍ឆ្នាំ១៩០០)
ស្ថិតនៅក្នុងភូមិសំរោង ឃុំពន្លៃ ស្រុកអង្គរបុរី ខេត្តតាកែវ។

# អារម្ភកថា

ភាពស្ងៀមស្ងាត់រយៈពេលវែងមួយបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងជំនាន់ខ្មែរក្រហម។ នេះជាភាពស្ងៀមស្ងាត់មួយដែលកើតមានជាច្រើនទសវត្សរ៍កន្លងមកហើយ និងបន្តរស់នៅក្នុងភាពភ័យខ្លាច ឈឺចាប់ និងនយោបាយ។

ទោះបីជាយ៉ាងដូច្នេះក្តី នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កិច្ចខិតខំប្រឹងប្រែងដ៏មោះមុត ដើម្បីបញ្ចប់ភាពស្ងៀមស្ងាត់នេះ បានធ្វើឡើងតាមទម្រង់យុត្តិធម៌ផ្លូវច្បាប់ កម្មវិធីចុះផ្ទាល់ទៅកាន់មូលដ្ឋាន និងការអប់រំពីអំពើប្រល័យពូជសាសន៍នៅតាមវិទ្យាល័យក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលវិធីសាស្ត្រនីមួយៗពិតជាមានតម្លៃចំពោះការព្យាបាលរបួសផ្លូវចិត្តនៅកម្ពុជា ក៏នៅមានតម្រូវការវិធីសាស្ត្រនានាខ្លះទៀត ដែលផ្តោតលើជាតុផ្សំផ្នែកអារម្មណ៍និងចិត្តសាស្ត្រនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត។ នេះគឺជាអ្វីដែលសិល្បៈអាចចូលរួមចំណែកយ៉ាងសំខាន់។ ខ្មែរក្រហមបានសម្លាប់សិល្បករជាច្រើននាក់ ប៉ុន្តែខ្មែរក្រហមមិនបានលុបបំបាត់ឈាមជ័រសិល្បៈរបស់ប្រជាជនកម្ពុជាបានឡើយ។ សិល្បៈ គឺជាដួងព្រលឹងរបស់យើង។

ល្ខោននិយាយដូចដែលបានលើកឡើងតាមរយៈចំណងជើង «ទម្លាយភាពស្ងៀមស្ងាត់» គឺមានគោលបំណងទម្លាយភាពស្ងៀមស្ងាត់នៅក្នុងប្រទេសកម្ពុជា។ ល្ខោននិយាយនេះ ជាការសម្តែងអំពីទុក្ខវេទនា កំហឹង និងឆន្ទៈក្នុងការបន្តទៅមុខរបស់ប្រជាជនកម្ពុជា ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ ជនរងគ្រោះនៃរបបខ្មែរក្រហម គឺជាបុគ្គលទាំងឡាយដែលបន្តរស់រានមានជីវិតទាំងការរបួសផ្លូវចិត្តនៅក្នុងសង្គមដ៏ខ្ទេចខ្ទាំមួយ ពោលគឺជាមនុស្សដែលពុំមានព្រលឹង ឬស្មារតីបន្តដំណើរទៅមុខទៀត។ ខ្ញុំបានរកឃើញព្រលឹងរបស់យើង តាមរយៈការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»។ ល្ខោននិយាយនេះ នឹងជួយស្តារកិត្តិសព្ទនិងភាពជាមនុស្សលើកកម្ពស់សីលធម៌ និងជួយដល់កូនចៅរបស់យើង ឲ្យយល់អំពីប្រទេសជាតិរបស់ខ្លួនកាន់តែប្រសើរជាងមុន។ ខ្ញុំសង្ឃឹមថាការសម្តែងនេះ ក៏ដូចជាការសម្តែងនានាក្នុងពេលអនាគតដែរ គឺនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារសង្គមកម្ពុជាសារជាថ្មី។

**ឆាំង យុ**

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា



# ការចាប់ផ្ដើមសរម្ដើង

ស្រែលាតអន្លាយ បត់ឆ្ងាយជើងមេឃ
ទឹកចាំងផ្លេកៗ ឃើញដើមត្នោតរាំ
កុកក្រៀលក្រសា ចឹកត្រីគ្រេងគ្រាំ
ក្របីដល់វែធ ទ្រហ៊ឹងអឹងអាប់...អឺយៗ

ត្រដេវឆាបឆេវ ចេញពីសូរិយា
កន្ទុំរុយដាច់ផ្ងារ ចូលពួនគុម្ពស្មៅ
កន្លបភ្នែកប្រាក់ ចូលសំងំនៅ ក្នុងស្មៅធ្វើហី
ត្រដេវហើរហួស...អឺយៗ

កុមារទាំងឡាយ នាំគ្នាដំកង់ ស្មារតីធ្វិតធ្វង់
លេងវែកបាយខុំ ខ្លះច្រៀងសកវាទ៍ លើដើមឈើធំ
ខ្លះពួនសំងំ ក្រោមម្លប់ត្រៃឈៃ...អឺយៗ

លុះពេលសូរិយា ជិតបាត់រស្មី
បក្សាបក្សីហើរទៅទ្រនំ
ដាហ្វូងដាជួរ មានតូចមានធំ
គោបាក៏នាំ សត្វចូលក្រោលផង...អឺយៗ

សន្ធ្យារាត្រី ដណ្ដប់លើវាលស្រែ
សត្វល្អិតទឹកកែ ក្អាត់ស្រែករំពង
តារានិករ ធ្លាក់ទឹករហង់
កសិករលក់លង់ នៅក្នុងនិទ្រា...អឺយៗ

## ♪ ចម្រៀង (សុខលី)

**សាធ ប៊ុនរិទ្ធ - ចម្រៀងសោកស្ដាយរបស់ប្រជាជនកម្ពុជា**

*ស្រណោះអ៊ើយកូនខ្មែរ ដូចលលកស្រែត្រូវព្យុះ*
*បោកដល់ត្រូវភ្លៀងត្រូវផ្គរ វេងាវសែនសល់ ទុក្ខសោក*
*នៅទល់នឹងកែវនេត្រា អ៊ើយ!។*

**~ សុវណ្ណា ~**
*មានរឿងរ៉ាវជាច្រើនដែលបានកើតឡើង ។ យើងត្រូវតែ*
*និយាយពីរឿងផ្ទាល់ខ្លួនរបស់ពួកយើង ។*

**~ ស៊ីណា ~**
*និយាយរឿងរបស់យើង យើងចង់និយាយ*
*គ្មានពេលល្ហែរ ។*

**~ សុខលី ~**
*ចុះរឿងហេតុអ្វីខ្មែរសម្លាប់ខ្មែរ ?*

**~ ធារី ~**
*ពេលនេះត្រូវតែជួយគិតខ្ញុំផង ។*



# ឈុតទី១

**វុត្ថា ~**
នេះគឺជារឿងរ៉ាវនៃការបែងចែកប្រជាជន

អ្នកគឺ សុភី។
អ្នកមានអាយុ៥២ឆ្នាំ។
អ្នកចង់ឮពីការពិត ហើយគ្មានអ្វីក្រៅពីការពិតដែរ។

អ្នកគឺធីតា។
អ្នកមានអាយុ៥៣ឆ្នាំ។
អ្នកមិនចង់និយាយ។ អ្នកមិនចង់ឮ ហើយអ្នកមិនចង់ឃើញ។

អ្នកគឺ អាគ្រាក់។
អ្នកមានអាយុ៥៨ឆ្នាំ។ អ្នកមិនអាចទទួលយកការពិតបានទេ។

**វុត្ថា ~**
តើលោកឯងមានតួនាទីធ្វើអីកាលពីជំនាន់ ប៉ុល ពត?

**ស៊ីណា/អាគ្រាក់ ~**
ខ្ញុំគឺជាប្រធានយុវជន។
ខ្ញុំអប់រំយុវជនឲ្យស្រលាញ់ប្រទេសជាតិ។

**វុត្ថា ~**
តើលោកមានចេញបញ្ជាឲ្យចាប់មនុស្សដែរអត់?

**ស៊ីណា/អាគ្រាក់ ~**
មាន... ពួកយើងមិនធ្វើមិនបានទេ។
សូម្បីតែពុកម៉ែ និងកូនខ្ញុំ ក៏ត្រូវគេយកទៅដែរ។
យើងមិនអាចធ្វើអ្វីបានទេ។

**វុត្ថា ~**
តើលោកជាមនុស្សសំខាន់ដែរឬក៏អត់?

**ស៊ីណា/អាគ្រាក់ ~**
អត់ទេៗ...ខ្ញុំនិយាយពិតមែន។ បញ្ជាថ្នាក់លើ មិនមែនធ្លាក់មក
ខ្ញុំដោយផ្ទាល់ទេ ព្រោះអីការងារខ្ញុំធ្វើនៅថ្នាក់ក្រោមឯណោះទេ។
ខ្ញុំអត់ចេះអក្សរ...អញ្ចឹងហើយខ្ញុំស្ថិតក្រោមការគ្រប់គ្រងរបស់គេ។
ខ្ញុំធ្វើតាមបញ្ជាតែប៉ុណ្ណោះ។

**វុត្ថា ~**
តើលោកដឹងពីរឿងសម្លាប់រង្គាលដែរ ឬក៏អត់?

**ស៊ីណា/អាគ្រាក់ ~**
រឿងសម្លាប់អីអស់ហ្នឹងនៅភូមិផ្សេងទេ...

**ធារី/សុភី ~**
ឯងកុហក!

**ស៊ីណា/អាគ្រាក់ ~**
នៅភូមិនេះ គ្មាននរណាត្រូវគេយកទៅសម្លាប់ទេ។
ខ្ញុំអត់មានបានធ្វើអីទេ។

**ធារី/សុភី ~**
កុហក!
ឯងមិនអាចប្រកែកថាមិនដឹងពីរឿងសម្លាប់មនុស្សនេះទេ។
អ្នកណាក៏គេដឹងពីរឿងកាប់សម្លាប់នេះដែរ។

**វុត្ថា ~**
«ដំរីស្លាប់ យកចង្អេរមកបាំងមិនជិតទេ»។

**សុខលី/ធីតា ~**
ឈប់ទៅ...កុំនិយាយជាមួយគាត់។ ខ្ញុំមិនចង់និយាយជាមួយ
មនុស្សអស់នេះទេ។

**ធារី/សុភី ~**
កាលណោះ អ្នកណាក៏ខ្លាចឯងដែរ។ គេថា បើឯងសម្លឹងដាក់អ្នក
ណាតែម៉ាភ្លែត ស្អែកឡើងម្នាក់នោះច្បាស់ជាបាត់ខ្លួនមិនខាន។

**ស៊ីណា/អាគ្រាក់ ~**
ប្រជាជន គេចេះតែថាហ្នឹង។ អត់មានភស្តុតាង។

**ធារី/សុភី ~**
ខ្ញុំចង់ឲ្យឯងនិយាយការពិត។ ឯងដឹងពីរឿងសម្លាប់មនុស្សនេះ
ហើយឯងក៏ពាក់ព័ន្ធនៅក្នុងរឿងហ្នឹងដែរ កុំប្រកែកឲ្យសោះ។

**ស៊ីណា/អាគ្រាក់ ~**
រឿងនេះកើតឡើងគ្រប់កន្លែងហ្នឹង។ ម្នាក់ៗស្ថិតក្រោម
ស្ថានភាពដូចគ្នា។ ពួកយើងទទួលបញ្ជាពីមេដឹកនាំជាន់ខ្ពស់។
យើងមិនហ៊ានប្រកែកទេ ព្រោះយើងខ្លាចស្លាប់។

**ធារី/សុភី ~**
ឯងខ្លាចស្លាប់? ចុះឯងមិនគិតថាពួកយើងខ្លាចស្លាប់ដែរទេអ្ហែស?

**សុខលី/ធីតា ~**
តើយើងអាចធ្វើអីបានទៅ? ប្រទេសបានធ្លាក់ទៅក្នុងរបត់
នោះទៅហើយ។

**ធារី/សុភី ~**
វិប្បដិសារីគ្មានដេរស្ដីឯងពីរឿងការស្លាប់របស់មនុស្សរាប់ម៉ឺននាក់
នោះទេអ្ហែស?

**ស៊ីណា/អាគ្រាក់ ~**
អត់ទេ...រឿងនេះមិនមែនប៉ះពាល់អីដល់សតិសម្បជញ្ញៈខ្ញុំទេ។
គេបានចងខ្ញុំជាប់ទៅនឹងអង្គការទៅហើយ... មិនថា វាគឺជាអំពើ
ប្រល័យពូជសាសន៍ ឬក៏មិនមែននោះទេ....

**ធារី/សុភី ~**
ដោយសារតែឯង ប្រជាជនត្រូវគេសម្លាប់។

**សុខលី/ធីតា ~**
ឈប់ប្រកែកគ្នាទៅ។ នៅពេលដែលអ្នកប្រកែកគ្នាខ្លាំងពេក
នោះឈាមហឹង្សាដែលកាប់សម្លាប់មនុស្សនឹងត្រឡប់មក
មនុស្សជំនាន់នេះម្ដងទៀត។ សូមឈប់និយាយ ហើយនាំគ្នា
ដឹករណ្ដៅមួយ ដើម្បីលុបវាចោល និងបំភ្លេចពីរឿង
អតីតកាលទៅ។

**ធារី/សុភី ~**
ឈាមស្រក់ច្រើនណាស់ ស្ទើរក្លាយទៅជាទន្លេទៅហើយ។
យើងមិនអាចបំភ្លេច ឬក៏លើកលែងទោសឲ្យពួកវាបានទេ។

**ស៊ីណា/អាគ្រាក់ ~**
ខ្ញុំមិនមែនសប្បាយប៉ុន្មានទេ។ ខ្ញុំក៏ឈឺចាប់ដែរ។ នៅពេលដែល
អង្គការដួលរលំទៅ ប្រជាជនដែលខឹងសម្បាមួយក្រុម បានដេញ
តាមខ្ញុំរហូតដល់ក្នុងព្រៃ។
ប៉ុន្តែនៅពេលដែលខ្ញុំត្រលប់មកវិញ ខ្ញុំត្រូវបានអ្នកភូមិគាំទ្រ។ គេ
ថែមទាំងបានឲ្យអាហារខ្ញុំហូបចុកទៀតផង។
គេមិនបានបាញ់ខ្ញុំសម្លាប់ចោលទេ។ មានន័យថាខ្ញុំអត់បានសម្លាប់
អ្នកណាឡើយ។ ខ្ញុំនៅតែមានជីវិតរស់ដល់សព្វថ្ងៃ។ ទាល់តែធ្វើ
បុណ្យកុសលល្អ ទើបយើងអាចរស់នៅបានយូរអង្វែង។

**ធារី/សុភី ~**
មិនមែនបុណ្យកុសលឯងទេដែលនាំឲ្យឯងមានជីវិតរស់នៅនោះ
គឺសាច់ញាតិបងប្អូនរបស់ជនរងគ្រោះ ដែលដើរតាមផ្លូវរបស់
ព្រះពុទ្ធឯណោះទៅវិញទេ។

**ស៊ីណា/អាគ្រាក់ ~**
ស្ដាប់ខ្ញុំ! ខ្ញុំត្រូវទៅឥឡូវនេះ។
ដល់ម៉ោងបាយហើយ។

**វុត្ថា ~**
ឈប់! មានគេចង់និយាយជាមួយឯង។
គាត់ឈ្មោះ ព្រាល។
គាត់មានអាយុ៥០ឆ្នាំ។
គាត់ស្នាក់ស្ទើរទាំងយប់ទាំងថ្ងៃ៖
ថាត្រូវសងសឹក ឬមិនសងសឹក។

**សុវណ្ណា/ព្រាល ~**
សាកសពឪពុកខ្ញុំនៅឯណា?
ឯងបានចាប់ខ្លួនគាត់?
ឯងបានសម្លាប់គាត់។
តើសាកសពគាត់នៅឯណា?
ខ្ញុំចង់បញ្ចុះសពឪពុកខ្ញុំ។

**ស៊ីណា/អាគ្រាក់ ~**
រឿងកាប់សម្លាប់អីអស់ហ្នឹង នៅភូមិផ្សេងទេ។

**សុវណ្ណា/ព្រាល ~**
ឯងកុហក!



# ចុះរឿងអ្វី
# ខ្មែរសម្លាប់ខ្មែរ?

**ស៊ីណា/អាគ្រាក់ ~**
ឯងមានភស្ដុតាងម៉ោពីណា...?

**សុវណ្ណា/ព្រាល ~**
ខ្ញុំបានឃើញឯង។

**ស៊ីណា/អាគ្រាក់ ~**
សូមទោស...ខ្ញុំត្រូវទៅហើយ....

**សុវណ្ណា/ព្រាល ~**
អត់ទេ។ ឯងត្រូវតែឆ្លើយ។ ឯងសម្លាប់ឪពុកខ្ញុំ
ប៉ុន្តែឯងមិនហ៊ានសារភាព។
នៅពេលដែលគាត់ចេញពីព្រៃមកវិញ ខ្ញុំគ្រាន់តែសួរគាត់ថា
"តើឪពុកខ្ញុំមានរឿងអី? តើឪពុកខ្ញុំនៅឯណា?"
គាត់ខ្លាចខ្ញុំសម្លាប់គាត់។ គាត់ថា គាត់មិនស្គាល់ឪពុកខ្ញុំទេ។
គាត់កុហក!
ខ្ញុំមានកាំភ្លើងមួយដើម ហើយគាត់ដឹងថាខ្ញុំប្រាកដជាបាញ់
សម្លាប់គាត់មិនខាន បើគាត់សារភាពថាបានសម្លាប់ឪពុកខ្ញុំ។
ខ្ញុំចង់សម្លាប់គាត់ណាស់។
ប៉ុន្តែ មិត្តភក្តិខ្ញុំម្នាក់បានប្រាប់ខ្ញុំថា មិនឲ្យសម្លាប់មនុស្សទេ ព្រោះ
ថានឹងមានកម្មពៀរដល់ខ្លួនខ្ញុំវិញ។ ដូច្នេះហើយ ខ្ញុំមិនសម្លាប់គាត់
ព្រោះខ្ញុំបារម្ភពីរឿងនោះ ប៉ុន្តែទោះជារហូតដល់សព្វថ្ងៃក៏ដោយ
ក៏រឿងរ៉ាវទាំងអស់នេះនៅស្ថិតក្នុងចិត្តខ្ញុំជានិច្ច។
បើកាលណោះខ្ញុំវាយធ្វើបាបគាត់ ប្រហែលជាគាត់ព្រមប្រាប់ខ្ញុំ
ពីការពិត ហើយខ្ញុំក៏ប្រហែលជាអាចបញ្ចុះសពឪពុកខ្ញុំបាន
ទៅហើយ។ ប៉ុន្តែខ្ញុំមិនបានធ្វើដូច្នេះឡើយ។
ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងម៉េចទេ។

ខ្ញុំដឹងថា ពៀររំងាប់ដោយការមិនចងពៀរ។ ការចងពៀរវេរានឹងគ្នា
គឺគ្មានថ្ងៃបញ្ចប់នោះទេ។ ខ្ញុំដឹងថាយើងមិនត្រូវសម្លាប់រាល់វត្ថុ សត្វ
រុក្ខជាតិទាំងអស់ដែលមានជីវិតនៅលើផែនដីយើងនេះ សូម្បីតែសត្វ
មូស ដែលខាំយើងក៏ដោយ។ ប៉ុន្តែខ្ញុំមិនមែនជាព្រះទេ ហើយ
រហូតដល់ថ្ងៃខ្ញុំស្លាប់ ខ្ញុំនៅតែអង្គុយនៅកន្លែងនេះ
និងមិនដឹងពីការពិតជារៀងរហូត។

**សុខលី/ធីតា ~**
អ្នកណាល្អ? អ្នកណាអាក្រក់?
តើអាក្រក់នោះវាអាក្រក់ប៉ុណ្ណាទៅ? តើល្អនោះវាល្អប៉ុណ្ណាទៅ?
តើថ្ងៃក្រោយទៅប្រទេសយើងនឹងទៅជាយ៉ាងណា សម្រាប់កូន
ចៅជំនាន់ក្រោយរបស់យើង?

### ♪ ចម្រៀង (វុត្ថា)

### អ៊ូ អឿ - មរណភាពរបស់ភរិយា

*បងស្លាប់ចោលអូន ជីវិតបងសូន្យទាំងឈឺខ្លោចផ្សា*
*ចោលអូនឯកឯងកណ្ដាលលោកា អូនពឹងនរណា*
*នរណាពីពេលនេះទៅ អូនពឹងនរណា*
*នរណាពីពេលនេះទៅ។*

*ធ្លាប់រួមធ្លាប់រស់ ចិត្តបងតែងស្មោះស្ម័គ្រលើអូនពៅ*
*ពេលនេះបងស្ងៀមឈាមបងហូរនៅ ជិតដាប់សាច់ពៅ*
*ពៅទុក្ខពៅទុក្ខខ្លោចផ្សា ជិតដាប់សាច់ពៅ*
*ពៅទុក្ខពៅទុក្ខខ្លោចផ្សា។*

*ឲ្យអូនខមាទោស អ្វីអូនធ្វើខុសសុំលើកទោសា*
*អូនកប់បងហើយណាអ្នកស្នេហា សូមស្រស់រៀមរ៉ា*
*ជីវ៉ាទៅសុគតិភព សូមស្រស់ជីវ៉ារៀមរ៉ា*
*ទៅសុគិតភព។*



# ឈុតទី២

**វុត្ថា ~**
នេះគឺជារឿងរ៉ាវស្ត្រីពីរនាក់ដែលកាលពីក្មេង ជីវិតរបស់ពួកនាងត្រូវបានបំផ្លាញ

អ្នកគឺ ស៊ីណា។
អ្នកមានអាយុ៤៣ឆ្នាំ។
អ្នកតែងតែនឹករឭកដល់ឪពុករបស់អ្នកជានិច្ច។

**ស៊ីណា ~**
នេះគឺជាឆ្នាំ១៩៧៦។
ខ្ញុំមានអាយុ១០ឆ្នាំ។
គេយកឪពុកខ្ញុំទៅមន្ទីរពេទ្យ។
ពុករបស់ខ្ញុំ គាត់មានសក់រួញអង្គាជី ជំស្រស់សង្ហា។
ពុកដ៏រឹងមាំរបស់ខ្ញុំ គាត់មានសម្បុរសណ្តែកបាយ។
ពុកមានជម្ងឺហើម។ មនុស្សយើងតែងតែហើមអញ្ចឹងនៅពេលអត់មានអីហូប។
នេះគេហៅថាជម្ងឺដែលបណ្តាលមកពីការអត់ឃ្លាន។
ខ្លួនរបស់ពុក ចេះតែហើមស្រកៗ។
ពុក គាត់តែងតែស្រែករកគេជួយ។ «ជួយផង! ជួយផង! ខ្ញុំចុកពោះខ្លាំងណាស់។»
ពេទ្យម្នាក់បានចេញមក រួចហើយក៏ស្រែកសម្លុតឲ្យពុកថា៖

**សុវណ្ណា/ពេទ្យ ~**
ថ្លង់ណាស់! យើងដេកមិនលក់ទេ!

**ស៊ីណា ~**
ម៉ែក៏បានលើកដៃសំពះទៅកាន់ពេទ្យនោះថា «មិត្តបង!មិត្តបង! សូមជួយប្តីខ្ញុំផង។ គាត់កាន់តែចុកពោះខ្លាំងហើយ»។
ពេទ្យនោះក៏លូកចូលទៅក្នុងហោប៉ៅរបស់គាត់ ហើយទាញបានថ្នាំមួយក្តាប់ធំពណ៌ខ្មៅ រួចហើយក៏ដើរចេញទៅ។
ម៉ែក៏យកថ្នាំនោះមកឲ្យពុក ប៉ុន្តែថ្នាំមិនបានធ្វើឲ្យពុកបាត់ឈឺពោះនោះទេ។ ពុកថ្ងូរឈឺ។
ពេទ្យនោះក៏ចេញមកម្តងទៀត ហើយក៏ស្រែកសម្លុតឲ្យពុក៖

**សុវណ្ណា/ពេទ្យ ~**
ហើយម៉េចក៏ស្រែកខ្លាំងៗម៉េសអ្ហាស! ចង់ងាប់អ្ហាស!

**ស៊ីណា ~**
ពុកស្រែកឈឺ។ ភ្នែកពុកឡើងលៀន។
ម៉ែអង្វរពេទ្យ «មិត្តបងអើយ មិត្តបង! សូមជួយប្តីខ្ញុំផង។ គាត់កាន់តែចុកពោះខ្លាំងហើយ»។
ពេទ្យនោះក៏ដើរសំដៅមករកពុក ដោយមានកាន់ថ្នាំមួយសេរ៉ាំងធំ ហើយក៏ចាក់ចូលទៅក្នុងសាច់របស់ពុក ពុកបាត់មាត់ឈឹង ហើយនៅស្ងៀម។
ម៉ែត្រកង និងឱបពុក។
ពេទ្យនោះក៏យកពិលមកបញ្ចាំងលើមុខម៉ែ

**សុវណ្ណា/ពេទ្យ ~**
នែ! មិត្តឯងធ្វើអីហ្នឹង? មិនឃើញប្តីមិត្តឯងងាប់ហើយទេអ្ហេស! ហើយចង់នៅឱបខ្មោចដល់ណាទៀត?

**ស៊ីណា ~**
ម៉ែអត់យំទេ!
ម៉ែគ្មាននិយាយអ្វីទាំងអស់។
ខ្ញុំមានអាយុ១០ឆ្នាំ ហើយចាប់ពីពេលនោះមក នៅក្នុងខ្លួនរបស់ខ្ញុំលែងមានអ្វីទាំងអស់។

**វុត្ថា ~**
អ្នកគឺ សម្ផស្ស។
អ្នកមានអាយុ៤៨ឆ្នាំ។
អ្នកស្តាយភាពអាម៉ាស់ជាប់នឹងខ្លួន។

# ខ្ញុំដឹង! ខ្ញុំគួរតែអភ័យទោស

## ប៉ុន្តែគាត់សម្លាប់ឪពុកខ្ញុំ ហើយស្រែកដាក់ម្តាយខ្ញុំទៀត

**សុខលី ~**
ហេតុអីឯងមិនមកអង្គុយជិតយើង?

**សុវណ្ណា/ពេទ្យ ~**
ខ្ញុំមិនទៅអង្គុយជាមួយអ្នក ព្រោះខ្ញុំខ្មាស់គេ។

**សុខលី ~**
តើអ្នកបានស្តាប់រឿងរបស់ ស៊ីណា ដែរឬទេ?

**សុវណ្ណា/ពេទ្យ ~**
ខ្ញុំបានស្តាប់ឮអស់ហើយ។

**សុខលី ~**
បើអ្នកជួបជាមួយពេទ្យម្នាក់នោះដែលស្រែកសម្លុតម្តាយរបស់អ្នក តើអ្នកធ្វើដូចម្តេចទៅ?

**ស៊ីណា ~**
ខ្ញុំរត់ទៅឲ្យឆ្ងាយ។
ខ្ញុំនៅឲ្យស្ងៀមដូចជាម្តាយរបស់ខ្ញុំអញ្ចឹង។

**សុខលី ~**
បើអ្នកជួបក្មេងស្រីដែលអង្គុយជិតឪពុករបស់នាង ដែលជិតដាច់ខ្យល់ស្លាប់ ជាមួយម្តាយដ៏ស្ងៀមស្ងាត់របស់នាង តើអ្នកធ្វើដូចម្តេចទៅ?

**សុវណ្ណា/ពេទ្យ ~**
ខ្ញុំនឹងដើរចូលផ្ទះវិញ ហើយទាញទ្វារបិទតិចៗ។

**សុខលី ~**
នាងនៅទីនេះ គឺជាពេទ្យ។
តើអ្នកនៅចាំគាត់បានអត់?
ខ្ញុំគិតថាគាត់ក៏ចង់និយាយរឿងរ៉ាវប្រាប់យើងដែរ។

**សុវណ្ណា/ពេទ្យ ~**
នៅឆ្នាំ១៩៧៦។
ខ្ញុំមានអាយុ១៥ឆ្នាំ។
ពេលនោះមានក្មេងស្រីជាច្រើននាក់បានមកធ្វើជាគ្រូពេទ្យ ដើម្បីបម្រើដល់បដិវត្តន៍។ ខ្ញុំសប្បាយចិត្តណាស់ ព្រោះនេះគឺជាក្តីសុបិន្តរបស់ខ្ញុំ។ ខ្ញុំជាអ្នកមើលថែអ្នកជម្ងឺ។ ខ្ញុំបានក្លាយជាគ្រូពេទ្យនៅអាយុ១៥ឆ្នាំប៉ុណ្ណោះ។
ខ្ញុំខំប្រឹងធ្វើការខ្លាំងណាស់។
ខ្ញុំមានមោទនភាពមែនទែន។ គេថែមទាំងអនុញ្ញាតិឲ្យខ្ញុំនឹងចាក់ថ្នាំឲ្យអ្នកជម្ងឺទៀតផង។ ប៉ុន្តែបន្តិចក្រោយមកខ្ញុំមើលឃើញថាខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ព្រោះមន្ទីរពេទ្យនោះ មិនបានធ្វើអ្វីដែលមន្ទីរពេទ្យនោះគួរធ្វើនោះទេ។ យើងធ្វើការនៅទីនោះ គឺគ្រាន់តែបើកភ្នែកចាំមើលតែមនុស្សស្លាប់តែប៉ុណ្ណឹង។ យើងគ្មានអ្វីផ្តល់ឲ្យអ្នកជម្ងឺទាល់តែសោះ សូម្បីតែថ្នាំសង្កូវ។ គឺមានតែថ្នាំដែលមានរូបរាងដូចអាចម៍ទន្សាយតែប៉ុណ្ណឹង។ វាគ្មានជួយអ្វីដល់ពួកគេបានទេ។
ទាំងអស់នេះ សុទ្ធតែជាកំហុស។ ខ្ញុំមានអារម្មណ៍ច្របូលច្របល់ ហើយខឹងសម្បា។ ខ្ញុំខឹងខ្លាំងណាស់។
ខ្ញុំចង់រ៉េរ៉ៃគ្រែ ខ្ញុំចង់រ៉េអ្វីៗគ្រប់យ៉ាងទាំងអស់។
ខ្ញុំស្អប់ខ្មែរក្រហម។ ខ្ញុំស្អប់អ្នកជម្ងឺដែលស្លាប់ម្នាក់ហើយម្នាក់ទៀត។
ខ្ញុំចង់រត់គេចតែវាមិនអាចទៅរួច។
ខ្ញុំបានធ្លាក់ទៅក្នុងស្ថានភាពដ៏អាក្រក់នេះ។
ថ្ងៃមួយ ខ្ញុំបានធ្វើឲ្យសេរ៉ាំងម្ជុលធ្លាក់ដោយអចេតនា នោះគឺជាកំហុសមួយដ៏ធំ។ ប្រធានពេទ្យចោទខ្ញុំថា គឺជាជនក្បត់ហើយគាត់ព្រមានខ្ញុំថាបើខ្ញុំធ្វើឲ្យធ្លាក់សេរ៉ាំងម្ជុលនេះម្តងទៀត គេនឹងយកខ្ញុំទៅរៀនសូត្រ
ចាប់តាំងពីថ្ងៃនោះមក ខ្ញុំរង់ចាំស្តាប់តែបញ្ជាគេរហូត។
ខ្ញុំក្លាយខ្លួនដូចជាមនុស្សយន្តអញ្ចឹង។
ក្នុងដៃខ្ញុំមានថ្នាំអាចម៍ទន្សាយ និងសេរ៉ាំង។
ទីបំផុត ពួកយើងត្រូវបានរំដោះ។
ខ្ញុំបានត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំវិញ។
បន្តិចក្រោយមក ខ្ញុំក៏រៀបការ។
ខ្ញុំអត់បានក្លាយទៅជាពេទ្យនារី ដូចកាលដែលខ្ញុំស្រមៃពីក្មេងនោះទេ។
ប្តីរបស់ខ្ញុំជាមនុស្សស្ងៀមស្ងាត់ម្នាក់
ហើយពួកយើងក៏មានកូនដែលប្រកបដោយគន្លងធម៌ល្អ។
ពួកយើងរស់នៅយ៉ាងស្ងៀមស្ងាត់។

**សុខលី ~**
អញ្ចឹង! តើអ្នកអាចនិយាយទៅកាន់ស្រ្តីម្នាក់នេះបានទេថា អ្នកសោកស្តាយណាស់ដែលមិនបានជួយឪពុករបស់គាត់។

**សុវណ្ណា/ពេទ្យ ~**
តើខ្ញុំអាចធ្វើអ្វីបានទៅ បើពួកយើងគ្មានអ្វីដែលអាចជួយគាត់បានទាល់តែសោះ។ ហើយបើអង្ករ១កំប៉ុងសម្រាប់គ្នា ២០នាក់។ អញ្ចឹងហើយបានជាពួកគេស្លាប់។ ទោះបីជាមានថ្នាំសង្កូវ ក៏មិនអាចជួយពួកគេបានដែរ។ តើខ្ញុំអាចជួយអីពួកគេបានទៅ? ខ្ញុំដូចសត្វនៅក្នុងទ្រុងអញ្ចឹង។

**សុខលី ~**
អ្នកគួរតែនិយាយពាក្យថា សុំទោស ទៅកាន់នាងទៅ!

**សុវណ្ណា/ពេទ្យ ~**
អត់ទោសឲ្យខ្ញុំផង ដោយសារកាលនោះពួកយើងគ្មានថ្នាំហើយខ្ញុំក៏គ្មានសិទ្ធិអ្វីទាំងអស់។ ឲ្យខ្ញុំសុំទោស។

**សុខលី ~**
តើអ្នកទទួលយកការសុំទោសនេះដែរអត់?

**ស៊ីណា ~**
ខ្ញុំដឹង! ខ្ញុំគួរតែអភ័យទោសឲ្យគាត់។ ប៉ុន្តែគាត់បានសម្លាប់ឪពុកខ្ញុំ ហើយបានស្រែកសម្លុតឲ្យម្តាយខ្ញុំ។ ខ្ញុំពិបាកសម្រេចចិត្តណាស់។ ខ្ញុំមិនដឹងដោះស្រាយស្ថានភាពនោះបែបណាទេ? ហើយខ្ញុំក៏មិនដឹងថានិយាយយ៉ាងម៉េចដែរ។

**វុត្ថា (ច្រៀង) ~**
*សូមចាកចេញពីវង្វាស់នៃពេលវេលា សំដៅទៅរករង្វង់នៃសេចក្តីស្រឡាញ់។*

**សុវណ្ណា/ពេទ្យ**
បេះដូងខ្ញុំខុសប្លែកពីធម្មតា។ បេះដូងខ្ញុំស្រាប់តែគាំង។ ក្នុងមួយជីវិតនេះ ខ្ញុំខ្មាស់ខ្លួនឯងណាស់ ហើយខ្ញុំក៏មិនដែលភ្លេចដែរ។
នេះជាលើកទីមួយហើយ ដែលខ្ញុំនិយាយអំពីដំណើររឿងរបស់ខ្ញុំ។
អរគុណណាស់! អ្នកបានទម្លាយរឿងដែលលាក់នៅក្នុងចិត្តខ្ញុំកន្លងមក។
ខ្ញុំមានសង្ឃឹម គឺក្តីសង្ឃឹមដ៏តិចតួចដែលគេនឹងអត់ទោសឲ្យខ្ញុំ។

**ស៊ីណា ~**
ខ្ញុំព្យាយាមអភ័យទោស។ ខ្ញុំចង់អភ័យទោសឲ្យគាត់ខ្លាំងណាស់។ ប៉ុន្តែយើងមិនត្រូវបំភ្លេចនូវរឿងរ៉ាវដែលបានកើតឡើងបាននោះទេ។ បើយើងបំភ្លេច គឺយើងហាក់ដូចជាបាត់បង់ ពុក ម៉ែ កូន បង ប្អូន មីង មា ដោយទទេៗអញ្ចឹង។

### ♪ ចម្រៀង (ទាំងអស់គ្នា)

### ការចងចាំ

*ការចងចាំជាច្រើន ។ វាចេះតែវិលទៅវិលមក*
*ដូចជាកាំកង់ដែលកំពុងវិលអញ្ចឹង ។*
*តែងតែមានលក្ខណៈដូចគ្នាជានិច្ច ។ ដូចជាកាំកង់.....*
*កង់វិលនៅក្នុងក្បាលរបស់ខ្ញុំ ។*



# ឈុតទី៣

**វុត្ថា ~**
នេះគឺជារឿងរ៉ាវអំពើឧក្រិដ្ឋ និងភាពអាម៉ាស់
ដែលគ្មានថ្ងៃបញ្ចប់

អ្នកគឺ លោក រិទ្ធី។
អ្នកមានអាយុ៥១ឆ្នាំ។
អ្នកបាត់បង់នូវក្តីប្រាថ្នាក្នុងជីវិត។

ហើយអ្នកគឺជា ម្តាយរបស់លោក រិទ្ធី។
អ្នកមានអាយុ៧៦ឆ្នាំ។
អ្នកគឺជាអ្នកការពារកូនរបស់ខ្លួន។

**សុវណ្ណា/ម្តាយ ~**
យើងរស់នៅក្នុងភាពលំបាកលំបិន។
កូនខ្ញុំមានបញ្ហាក្បាល។ វាចេះតែបោកទង្គិចក្បាលរបស់វា
មើលទៅហាក់បីដូចជាក្បាលរបស់វាកំពុងធ្វើឲ្យវាឈឺចាប់អញ្ចឹង។
កូនខ្ញុំមានជម្ងឺ ហើយជម្ងឺនេះមានទាក់ទងទៅនឹងការលំបាក
វេទនារបស់វាតែម្តង។
កូនខ្ញុំមិនមែនជាមនុស្ស អាក្រក់ទេ។
វាមិនធ្លាប់ធ្វើអំពើអាក្រក់ទាល់តែសោះ។
ប៉ុន្តែមានថ្ងៃមួយនោះ នៅពេលដែលគេចាប់កូនខ្ញុំយកទៅដាក់គុក
គឺថ្ងៃនោះហើយដែលបានបំផ្លាញជីវិតពួកយើង។

**ធារី ~**
គេចាប់ឯងយកទៅដាក់គុកអ្ហ៎?

**សុវណ្ណា/ម្តាយ ~**
គេបានចងកូនខ្ញុំ។
គេចង់បានឈ្មោះ។

**សុខលី/រិទ្ធី ~**
ខ្ញុំអត់បានប្រាប់ឈ្មោះអ្នកណាទេ...

**សុវណ្ណា/ម្តាយ ~**
គេវាយកូនខ្ញុំខ្លាំងណាស់។

**ធារី ~**
ឯងបានប្រាប់ឈ្មោះទៅគេ?

**សុវណ្ណា/ម្តាយ ~**
គេធ្វើទារុណកម្មកូនខ្ញុំ។

**សុខលី/រិទ្ធី ~**
ខ្ញុំឲ្យឈ្មោះមនុស្សពីរនាក់ដល់ពួកវា។

**ធារី ~**
ឯងបង្កើបឈ្មោះមនុស្សច្រើនណាស់។

**សុវណ្ណា/ម្តាយ ~**
គេដុតដៃជើងកូនខ្ញុំ។

**ធារី ~**
ឯងបញ្ជូនមនុស្សទៅភូមិឆ្អឹងសច្រើនណាស់។

**សុខលី/រិទ្ធី ~**
គេចងខ្ញុំព្យួរក្បាលចុះក្រោម។
ខ្ញុំប្រាប់ឈ្មោះមនុស្ស៥នាក់ដល់ពួកគេ។
គេជ្រមុជទឹកខ្ញុំ។ ខ្ញុំប្រាប់ឈ្មោះមនុស្ស៨នាក់ដល់ពួកគេ។
គេយកខ្សែតីវាយខ្ញុំរហូតស្ទើរស្លាប់។

**សុវណ្ណា/ម្ដាយ ~**
កូនខ្ញុំវាយំដូចសត្វអណ្ដើកអាំងភ្លើងអញ្ចឹង។

**សុខលី/រិទ្ធី ~**
ខ្ញុំនឹកឃើញឈ្មោះអ្នកណា ខ្ញុំក៏ប្រាប់ទៅគេ។
១០នាក់ ២០នាក់ ៣០នាក់...ខ្ញុំប្រាប់ទាល់តែគេពេញចិត្ត។

**ធារី ~**
ឯងប្រាប់ឈ្មោះគេប្រហែលជា៣០នាក់។
បើក្នុងចំណោមនោះ ពួកគេម្នាក់ៗ និយាយតែឈ្មោះមនុស្ស ៣០ ឬ ក៏៤០នាក់នោះ ក្នុងរយៈពេលតែ១ឆ្នាំ ឬ២ឆ្នាំ ប្រាកដជាគ្មានសល់មនុស្សទេ។

**សុវណ្ណា/ម្ដាយ ~**
កូនខ្ញុំមិនចង់ធ្វើអញ្ចឹងទេ។
តើនរណាសម្លាប់នរណាទៅ? ខ្ញុំមិនដឹងទេ។

**សុខលី/រិទ្ធី ~**
ខ្ញុំគិតដល់អ្នកដែលត្រូវស្លាប់ជារៀងរាល់ថ្ងៃ។ ខ្ញុំបន់ព្រះថា បើខ្ញុំហៅឈ្មោះពួកគេ សូមព្រះជួយកុំឲ្យព្រលឹងរបស់គេរងទុក្ខពីការលំបាកនានាផង។
ពីមួយថ្ងៃទៅមួយថ្ងៃ វានៅតែធ្វើឲ្យអារម្មណ៍ខ្ញុំឈឺចុកចាប់។
វាដក់ក្នុងអារម្មណ៍ខ្ញុំជារៀងរាល់ថ្ងៃ។ ហេតុអ្វីបានជាមិនមែន ខ្លួនខ្ញុំជាអ្នកស្លាប់ទៅវិញ។

**វុត្ថា ~**
លោករិទ្ធី! បើមនុស្សម្នាក់ក្នុងចំណោមអ្នកដែលស្លាប់នៅមានជីវិតរស់នៅ តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ?
តើលោកនឹងធ្វើយ៉ាងម៉េច?

**សុខលី/រិទ្ធី ~**
បើអញ្ចឹងមែន ខ្ញុំពិតជាសប្បាយចិត្តណាស់ ។
ខ្ញុំនឹងលុតជង្គង់សុំឲ្យគាត់អត់ទោសឲ្យខ្ញុំ។

**សុវណ្ណា/ម្ដាយ ~**
ហើយសុំអ្នកដែលបានស្លាប់នោះឲ្យបណ្ដេញកម្មអាក្រក់ចេញឲ្យអស់។

**♪ ចម្រៀង** (វុត្ថា និងសុខលី)

**អ៊ូ អឿ — សម្បថ**

*បើខ្ញុំចោលម្សៀត អ៊ើយចោលម្សៀត*

*កុំទុករស់ទៀតនាំធ្ងន់ផែនដី នាំធ្ងន់ផែនដី បំភ្លេចខ្ញុំចុះ*

*ឲ្យលិចតាមថ្ងៃ បើនៅចង្រៃទឹកដីគោកធ្លក*

*ទឹកដីគោកធ្លក។*



# បើមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលស្លាប់នៅមានជីវិតរស់នៅ

តើលោកមានប្រតិកម្មយ៉ាងម៉េច? តើលោកនឹងធ្វើយ៉ាងម៉េច?





# ឈុតទី៤

**វុត្ថា ~**

នេះគឺជារឿងរ៉ាវរបស់និស្សិតម្នាក់ ដែលធ្លាប់ស្រមៃចង់បានពិភពលោកមួយដែលប្រសើរជាងមុន

អ្នកគឺជាលោក សារុន។
អ្នកមានអាយុ៥២ឆ្នាំ។
អ្នកបាត់បង់ក្តីស្រឡាញ់ពីម្តាយ។

**ធារី/និស្សិត ~**

ខ្ញុំឈ្មោះ សារុន ខ្ញុំរស់នៅតែម្នាក់ឯងប៉ុណ្ណោះ។
កាលពីតូចខ្ញុំគឺជាសិស្សល្អម្នាក់នៅឯសាលារៀនក្នុងភូមិនេះ។
ឪពុកម្តាយខ្ញុំមានមោទនភាពចំពោះខ្ញុំខ្លាំងណាស់ ។
ពុកខ្ញុំខិតខំធ្វើការ ដើម្បីឲ្យខ្ញុំអាចទៅរៀនសូត្រក្នុងសាកលវិទ្យាល័យនៅភ្នំពេញ។ គាត់តែងស្រមៃថា ខ្ញុំនឹងអាចក្លាយជាសាស្ត្រាចារ្យម្នាក់។ កាលណោះគឺជាជំនាន់ លន់ នល់ ហើយស្ថានភាពមិនល្អទាល់តែសោះ។ នៅក្នុងប្រទេសមានភាពវឹកវរសម្បើមណាស់ ។
និស្សិតដូចពួកខ្ញុំ គឺជាអ្នកដែលមានការស្រមើស្រមៃវែងឆ្ងាយ។
យើងចង់បានសង្គមមួយ និងពិភពមួយដែលល្អជាងនេះ។ យើងក៏បានធ្វើបាតុកម្មដ៏ធំមួយប្រឆាំងរដ្ឋាភិបាល ហើយពួកនិស្សិតជាច្រើននាក់ក៏ត្រូវបានគេចាប់ខ្លួន រួមទាំងរូបខ្ញុំផង។
នៅក្នុងគុកគេធ្វើទារុណកម្មខ្ញុំខ្លាំងណាស់។ គេវាយធ្វើបាបខ្ញុំ ហើយថែមទាំងឆក់ខ្សែភ្លើងខ្ញុំទៀតផង។ ប៉ុន្តែ ការដែលគេធ្វើបែបនេះគឺធ្វើឲ្យខ្ញុំស្អប់ លន់ នល់ កាន់តែខ្លាំងឡើង។
នៅពេលដែលគេដោះលែងខ្ញុំ ខ្ញុំក៏រត់ចូលព្រៃ គឺពេលនោះហើយដែលខ្ញុំបានជួបជាមួយខ្មែរក្រហម។ ខ្មែរក្រហមធ្វើការប្រយុទ្ធដើម្បីទទួលបាននូវសង្គមមួយដែលប្រសើរជាងនេះ គឺប្រទេសមួយដែលពោរពេញទៅដោយសេរីភាព គ្មានអំពើពុករលួយ ហើយគ្រប់គ្នាមានអាហារហូបចុកគ្រប់គ្រាន់។
ខ្ញុំពិតជាជឿជាក់អញ្ចឹងមែន។
ដូច្នេះខ្ញុំក៏ចង់ចូលរួមជាមួយគេឯងដទៃទៀត។ ខ្ញុំយល់ថាខ្ញុំមិនអាចបង្ហាញឲ្យគេដឹងថាខ្ញុំជាអ្នកដែលរៀនសូត្របានខ្ពស់នោះទេ។
ខ្ញុំខំធ្វើការដើម្បីឲ្យដៃខ្ញុំឡើងគ្រើម និងហាលថ្ងៃ ដើម្បីឲ្យសម្បុរខ្ញុំខ្មៅដូចអ្នកស្រែចម្ការ។ ខ្ញុំខំដាក់ខ្លួនធ្វើការឲ្យបានល្អ។
នៅទីបញ្ចប់ ខ្ញុំធ្វើអ្វីៗគ្រប់យ៉ាងតាមតែគេចង់បាន។ ខ្ញុំពួននៅក្រោមផ្ទះគេ ដើម្បីលួចស្តាប់គេនិយាយគ្នា។ ខ្ញុំចាប់មនុស្ស។ ខ្ញុំធ្វើរឿងអាក្រក់និងសាហាវជាច្រើន។ ខ្ញុំលែងគិតដូចមនុស្សទៀតហើយ។
ខ្ញុំប្រៀបដូចជាសត្វឆ្កែមួយក្បាល គឺចាំតែមើលមុខចៅហ្វាយនាយនិងបក់កន្ទុយដោយខ្លាចគេវ៉ៃ។

♪ **ចម្រៀង** (វុត្ថា)

**អ៊ូ អឿ — វប្បធម៌ធ្លាក់ចុះ**

*អស់ជាមនុស្សហើយ ពីពេលនេះអើយ*
*គ្មានទេពេលយប់ គ្មានទេពេលថ្ងៃឆ្លងវាល*
*អវីចី សែនអនិច្ចា មិនដឹងយ៉ាងណា*
*ណាព្រះអើយ។*

**ធារី/សារុន ~**
បន្ទាប់ពីបដិវត្តន៍ចប់ ខ្ញុំបានត្រឡប់ទៅកាន់ស្រុកកំណើតខ្ញុំវិញ។ ឥឡូវនេះ ខ្ញុំរស់នៅដោយខ្លួនឯង។ ខ្ញុំបង្រៀននៅឯសាលាបឋមសិក្សាដែលខ្ញុំធ្លាប់រៀនកាលពីមុន។
ខ្ញុំឮគេថា ខ្មែរក្រហមសម្លាប់ឪពុកខ្ញុំ នៅពេលដែលគាត់កំពុងធ្វើការនៅវាលស្រែ។ ពុកដ៏ស្លូតបូតរបស់ខ្ញុំដែលធ្លាប់តែស្រមៃថាខ្ញុំនឹងក្លាយទៅជាសាស្ត្រាចារ្យម្នាក់។ គេវាយគាត់រហូតដល់ស្លាប់ ដោយសារតែគាត់ខ្សោយពេកគ្មានកម្លាំងធ្វើការ។
ជួនកាលខ្ញុំខឹង ហើយជួនកាលខ្ញុំក្រៀមក្រំ។
ក្នុងក្បាលរបស់ខ្ញុំពោរពេញដោយភាពរញ៉េរញ៉ៃ។
ខ្ញុំមិនយល់ តើប្រទេសទាំងមូលត្រូវបានគេបោកបញ្ឆោតយ៉ាងដូចម្ដេចទៅ?
តើខ្ញុំត្រូវបានគេបោកបញ្ឆោតយ៉ាងដូចម្ដេចទៅ?
ត្រូវហើយ! ខ្ញុំបន្ទោសខ្មែរក្រហមចំពោះការដែលគេនាំខ្ញុំឲ្យដើរផ្លូវខុស ប៉ុន្តែវាក៏ជាកម្មរបស់ខ្ញុំដែរ ដូច្នេះខ្ញុំមិនអាចធ្វើអ្វីបានឡើយក្រៅពីបន្ទោសខ្លួនឯង។
ខ្ញុំទៅផ្សារ ហើយឃើញម៉ែខ្ញុំ។ គាត់អត់មានរាក់ទាក់ដាក់ខ្ញុំទេ។ គាត់បែរជាឈ្ងោកមុខ ហើយដើរចេញទៅ។ ខ្ញុំចង់ប្រាប់គាត់ថាខ្ញុំត្រូវការគាត់។

**វុត្ថា ~**
អ្នក គឺជាម្ដាយរបស់ សារុន។
អ្នកមានអាយុ៧៥ឆ្នាំ។
អ្នកបាត់បង់ក្ដីស្រឡាញ់ពីកូន។

**សុវណ្ណា/ម្ដាយ ~**
ខ្ញុំទៅផ្សារ។ ឲ្យតែដឹងថាកូនខ្ញុំនៅផ្សារ ខ្ញុំតែងតែទៅរកវាជានិច្ច។ ប៉ុន្តែនៅពេលដែលកូនសម្លឹងមើលមកខ្ញុំ ខ្ញុំមិនអាចសម្លឹងមើលទៅកាន់កូនវិញទេ ហើយខ្ញុំក៏ដើរចេញទៅ។
ខ្ញុំខ្មាស់គេដែលមានកូនបែបនេះ។ ប្ដីរបស់ខ្ញុំត្រូវគេវាយរហូតដល់ស្លាប់ ហើយខ្ញុំថែមទាំងបាត់បង់កូនទៀត នៅពេលដែលកូនខ្ញុំបានក្លាយទៅជាពេជ្ឈឃាតម្នាក់។
ខ្ញុំឮថា ឥឡូវនេះកូនខ្ញុំជាគ្រូបង្រៀនដ៏ល្អម្នាក់ វាមិនដែលវាយក្មេងៗហើយតែងតែអត់ធ្មត់ពន្យល់ក្មេងៗជានិច្ច។ នៅពេលដែលឮដំណឹងនេះ ខ្ញុំក៏លួចមានមោទនភាពចំពោះកូនខ្ញុំដែរ។
នៅពេលដែលកូនសម្លឹងមើលមកខ្ញុំរាល់ពេលដែលវាទៅផ្សារ ខ្ញុំដឹងថាវាចង់ឲ្យខ្ញុំអត់ទោសឲ្យវា ប៉ុន្តែពិបាកណាស់។

**ស៊ីណា ~**
ម្ដាយ និងកូននៅឈរស្ងៀមមួយកន្លែង។
ពួកគេនៅស្ងៀមទ្រឹងមួយស្របក់។
បន្ទាប់មក កូនក៏ដើរសំដៅទៅរកម្ដាយ ហើយគាត់ឱននិយាយថា៖

**ធារី/សារុន ~**
ម៉ែ...អត់ទោសឲ្យខ្ញុំផង...ខ្ញុំបានធ្វើអំពើអាក្រក់.. ឲ្យខ្ញុំសុំទោស។
តើធ្វើម៉េចទៅទើបខ្ញុំអាចលាងបាបនេះបានណាម៉ែ?

**សុវណ្ណា/ម្ដាយ ~**
វាមិនដូចមុនទេ.....
វាមិនដូចមុនទេ.....

## ♪ ចម្រៀង (វុត្ថា)

### បទ សំណោកខ្មោចទួញ

*ឱ! ស្នេហ៍បងអើយ! អឹងអើយៗ អន្ទោកអន្ទោល*
*ឲ្យបងទុក្ខឥតស្រាកស្រាន្តអំណឹះតទៅៗ*
*កពបងផ្សេងហើយ ពេលនេះចុងឈើៗ*
*ស្ពានបងរហូតហើយ។*

*ចាំស្ដាប់សំណោក បងតាមខ្យល់ចុះ*
*មើលទុក្ខព្រួយបង តាមមេឃស្រទំ ស្ទាបទឹកភ្នែកបងៗ*
*តាមទឹកភ្លៀងឱណាស្នេហ៍ណាៗ*
*ស្នេហ៍សម្លាញ់ចិត្ត!*

ខ្ញុំមិនយល់ តើប្រទេសទាំងមូលត្រូវបានគេ

# បោកបញ្ឆោតយ៉ាងដូចម្ដេចទៅ?







# ឈុតទី៥

**វុត្ថា ~**
នេះគឺជារឿងរ៉ាវរបស់ក្មេងស្រីម្នាក់ ដែលគាត់ចង់និយាយពាក្យសុំទោសតែមិនអាចទៅរួច

អ្នក គឺអ្នកស្រី សោភ័ណ្ឌ។
អ្នកស្រីមានអាយុ៣៨ឆ្នាំ។

**សុខលី/សាភ័ណ្ឌ ~**
នេះគឺជាឆ្នាំ១៩៧៦។
ខ្ញុំអាយុ៧ឆ្នាំ។ យើងរស់នៅក្នុងខ្ទមតូចមួយ មានម៉ែ បងប្រុសខ្ញុំពីរនាក់ ប្អូនស្រីតូចរបស់ខ្ញុំ និងខ្ញុំ។
យប់មួយនោះ ខ្ញុំភ្ញាក់ដឹងខ្លួនឡើង ខ្ញុំឃ្លានខ្លាំងណាស់។
កាលណោះ ខ្ញុំឃើញជន្លេនធាត់មួយ ខ្ញុំចង់ហូបវាណាស់ ប៉ុន្តែនៅពេលដែលវា វារក្នុងមាត់ខ្ញុំ ខ្ញុំក៏ខ្ជាក់វាចេញ ហើយក្អួត។
ឥឡូវនេះខ្ញុំកូរពោះខ្លាំងណាស់។
ខ្ញុំក៏នឹកឃើញដល់ពាងអង្ករដែលពុកបានលាក់អង្ករដែលនៅសេសសល់បន្តិចបន្តួច។ ពុកថាអង្ករនេះ គឺសម្រាប់ហូបនៅពេលដែលចាំបាច់បំផុត។ គាត់លាក់អង្ករនោះទុកតាំងពីមុនពេលគេយកគាត់ទៅរៀនសូត្រម្ល៉េះ។
នឹកឃើញដល់ពាងអង្ករខ្ញុំស្រមៃដល់រសជាតិដ៏ឆ្ងាញ់របស់អង្ករ។
ហាក់ដូចជាមានអ្វីធ្វើឲ្យខ្ញុំដើរទៅកាន់ពាងអង្ករ។ គ្មានអ្វីអាចបញ្ឈប់ខ្ញុំបានទេ។ ខ្ញុំក៏ភ្ញាក់ឡើង ហើយដើរលបៗ កាត់អ្នកដទៃទៀតដែលកំពុងដេកលក់។
ពោះខ្ញុំកូរខ្លាំងណាស់។ ខ្ញុំប្រឹងអត់ដង្ហើម។ តើមាននរណាឮពោះខ្ញុំកូរដែរអត់ហ្ន៎? គ្មានអ្នកណាឮទេ។
គេដេកលក់អស់ហើយ។
ដៃរបស់ម្ដាយខ្ញុំ កំពុងត្រកងប្អូនស្រីរបស់ខ្ញុំជាប់ ហើយមុខគាត់ឡើងហើមដោយសារការអត់ឃ្លាន។

លប....លប....អីយ៉ាស់ៗ ខ្ញុំមានអារម្មណ៍ថាដៃខ្ញុំប៉ះពាងអង្ករហើយ។ ខ្ញុំប្រឹងអត់ដង្ហើម។
ខ្ញុំបើកគំរបពាងអង្ករយឺតៗ។
ដៃខ្ញុំលូកចូលទៅក្នុងពាង ច្បាមយកអង្ករមួយក្ដាប់ ហើយក៏ប្រញាប់ដាក់ចូលទៅក្នុងមាត់ដែលកំពុងឃ្លាន។ ខ្ញុំបៀមអង្ករក្នុងមាត់។
នៅពេលដែលអង្ករទន់ល្មមហើយ ទើបខ្ញុំទំពារ។ អង្ករមានរសជាតិផ្អែមឆ្ងាញ់ណាស់ ហើយស្រួលលេបទៀត។ ខ្ញុំចង់ហូបហើយហូបទៀត។ ព្រឹកឡើង ប្អូនស្រីរបស់ខ្ញុំស្រែកឡើងថា......

**ធារី ~**
ម៉ែៗ មើលហ្ន! យប់មិញមានអ្នកណាបើកពាងអង្ករ។

**សុខលី/សាភ័ណ្ឌ ~**
ខ្ញុំក្រឡេកមើលទៅពាងអង្ករ ហើយឃើញគម្របពាងចំហរឡើង។
ខ្ញុំអត់បានបិទវាឲ្យបានស្រួលបួលទេ។
ម៉ែនិយាយថា៖

**សុវណ្ណ/ម្ដាយ ~**
ប្រហែលជាកណ្ដុរចូលស៊ីហើយ។ ចាំយប់នេះម៉ែនឹងបិទឲ្យជិត ព្រោះអង្ករនេះជារបស់យើងទាំងអស់គ្នា។

**សុខលី/សាភ័ណ្ឌ ~**
ខ្ញុំចង់ស្រែកប្រាប់ម៉ែថា៖ ម៉ែ! គឺខ្ញុំ...ខ្ញុំគឺជាអ្នកលួចអង្កររបស់គ្រួសារ។ សូមម៉ែអត់ទោសឲ្យខ្ញុំផងណាម៉ែ។
ប៉ុន្តែខ្ញុំអត់បាននិយាយអ្វីទាំងអស់។
ខ្ញុំជាមនុស្សមិនល្អ។ ខ្ញុំក៏ដឹងថា ម៉ែដឹងថាខ្ញុំជាអ្នកលួចអង្ករដែរ។
មានពេលមួយ ម៉ែធ្លាប់ប្រាប់កូនៗថា យើងត្រូវធ្វើជាមនុស្សល្អ។ អំពើអាក្រក់ដែលយើងបានសាងនោះ វានឹងតបស្នងមកវិញនូវបាបកម្ម ហើយជាតិក្រោយ យើងនឹងកើតជាពស់

ខ្យង ឬ ដង្កូវ។ ប៉ុន្តែបាបកម្ម វានឹងសាបសូន្យទៅវិញ នៅពេលដែលយើងហ៊ានសារភាព និងទទួលទោស។
ខ្ញុំចង់សារភាពណាស់។ ខ្ញុំចង់ទទួលទោសណាស់។
ប៉ុន្តែខ្ញុំអត់បាននិយាយអ្វីទាំងអស់។ ខ្ញុំនៅស្ងៀម គឺនៅស្ងៀមឈឹង។
ខ្ញុំចង់សារភាព។ ខ្ញុំចង់ទទួលទោស។ ខ្ញុំមិនបាននិយាយអ្វីសោះ។
ខ្ញុំស្អប់ម៉ែណាស់ ដែលម៉ែមិនដាក់ទោសខ្ញុំ ហើយខ្ញុំក៏ស្អប់ខ្លួនឯងដែរ ដែលខ្ញុំស្អប់ម៉ែ។

♪ ចម្រៀង (សុខលី)

**បទបំពេ "ទឹកចិត្តម្តាយ"**

*ឱ!នេះហើយ ឱចិត្តម្តាយ ទោះជិតឬឆ្ងាយ*
*គិតមិនសោះសូន្យ អាក្រក់ឬល្អក៏នៅតែកូន នេះហើយ*
*ជាក្បួន ចងកូនហើយនឹងម្តាយ។*
*ហាអ៊ើយ! នេះហើយជាក្បួន ចងកូនហើយ*
*នឹងម្តាយ។*

**សុខលី/សាភ័ណ្ឌ ~**
ឥឡូវនេះខ្ញុំអាយុ ៣៩ ឆ្នាំហើយ។
ប្អូនតូចខ្ញុំស្លាប់ដោយសារតែវាអត់មានអីហូបនៅឆ្នាំ១៩៧៧ ហើយបន្តិចក្រោយមក ម៉ែខ្ញុំក៏ស្លាប់ដែរ។ គេស្នើបងប្រុសខ្ញុំឲ្យចូលក្នុងកងយុវជន។ ខ្ញុំមិនដែលទទួលដំណឹងអ្វីពីគាត់ទាល់តែសោះ។
ខ្ញុំនៅមានជីវិត។
ជីវិតរបស់ខ្ញុំក៏ល្អគ្រាន់បើដែរ។ ខ្ញុំបានរៀនសូត្រ ហើយបានក្លាយទៅជាវេជ្ជបណ្ឌិតដ៏ល្អម្នាក់។ រាល់ពេលយប់ត្រជាក់ខ្ញុំតែងតែនឹកឃើញកំហុសរបស់ខ្លួនឯង។ ខ្ញុំដឹងថាកាលនេះ ខ្ញុំនៅជាក្មេងតូចនៅឡើយ។ ខ្ញុំដឹងថាភាពស្រេកឃ្លាន អាចផ្លាស់ប្តូរមនុស្សឲ្យក្លាយទៅជាសត្វ។ ហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាងឲ្យតែបានហូប។ ប៉ុន្តែកំហុសធ្ងន់ដែលខ្ញុំបានសាង វាជិតជាប់នៅក្នុងបេះដូងខ្ញុំជានិច្ច មិនអាចបំភ្លេចបានទេ។ បើមាននរណាម្នាក់មកជួយខ្ញុំ មិនដឹងជាល្អយ៉ាងណាទេ។ ហើយបើម៉ែរស់ឡើងវិញមិនដឹងជាល្អយ៉ាងណាទេ ដើម្បីឲ្យខ្ញុំបានសារភាពនៅចំពោះមុខគាត់ នូវបាបកម្មដែលខ្ញុំបានសាង ហើយខ្ញុំមិនហ៊ានសារភាពកាលខ្ញុំអាយុ ៧ ឆ្នាំ។

♪ ចម្រៀង (វុត្ថា)

*សូមឲ្យដើមពោធិ៍ មានសេរីភាព មានសេរីភាព*
*ក្នុងក្តីលូតលាស់។ សូមឲ្យស្គរគ្មោត ជៀសពីការជេរស្តីចុះ*
*ខ្មោចព្រាយទាំងអស់ ចេញឆ្ងាយរៀងរាពីប្រទេសខ្ញុំ*
*ប្រទេសកម្ពុជាឈប់មានវេរា នេះតទៅទៀត។*
*សូមឲ្យក្តីសុខ សុខសន្តិភាព ជូនប្រជាជាតិ នៅលើដីនេះ*
*ជូនប្រជាជាតិ នៅលើដីនេះ។*



# អំពើបាបនឹងសាបសូន្យទៅវិញ

## នៅពេលដែលយើងហ៊ានសារភាព និងទទួលកំហុស





# ឈុតទី៦

**វុត្ថា ~**
នេះគឺជារឿងរ៉ាវរបស់ក្មេងស្រីម្នាក់ដែលលែងនិយាយ
អ្វីទាំងអស់

អ្នកគឺជាអ្នកជិតខាង ឈ្មោះ រី។
អ្នកគឺជាអ្នកជិតខាង ឈ្មោះ រ៉ា។
អ្នកគឺជាអ្នកជិតខាង ឈ្មោះ រិន។

## ♪ ចម្រៀង

**(វុត្ថា, សុវណ្ណា, ធារី, សុខលី)**

**ទេពអប្សរសម្លេងរបាំស្ថានសួគ៌**

*កេសារំសាយ អណ្តែតសាយភាយ ចាំងពណ៌សុវណ្ណ*
*សម្ផស្សពណ៌ភ្លុក ចក្ខុភាំងភាន់ រេរាំពើតព័ន្ធ*
*របាំអំបៅ។*

*វាយោរំភើយ ធម្មជាតិផ្តល់ឲ្យ បែតងវាលស្មៅ*
*ឥតបីហ្មងសៅ ទ្របាទទេពកញ្ញា គយគន់យូរទៅ*
*ជាប់នៅនេត្រា។*

*ព្រះជាសាក្សី គុជកេវ្តនាគបីរបាំសួគ៌ា*
*ស្តែងថ្ងៃព្រហស្បតិ៍ឲ្យខ្ញុំទស្សនា ទុកជាទ្រព្យា*
*អង្គអញតទៅ។*

**វុត្ថា ~**
អ្នកគឺ ជា។
អ្នកមានអាយុ៤៧ឆ្នាំ។
អ្នកមិនចង់ឲ្យអ្នកណាឃើញអ្នកឡើយ។

**សុវណ្ណា/អ្នកជិតខាង ~**
នេះគឺជាឆ្នាំ១៩៧៦។
ជា គឺជានារីជំទង់ម្នាក់។
នាងមានអាយុ១៣ឆ្នាំ។
ជា មានរូបសម្ផស្សស្អាតណាស់។
រូបរាងដ៏ទន់ភ្លន់របស់នាងបង្ហាញអំពីការចាប់ផ្តើមក្លាយ
ខ្លួនជានារីក្រមុំម្នាក់។
នាងមានសក់រួញអង្គាដី ស្បែករលោង បបូរមាត់ពេញ
ភ្នែកមូលធំពណ៌ត្នោត និងរោមភ្នែកវែងៗ។

**ធារី/អ្នកជិតខាង ~**
នៅពេលដែលនាងធ្វើដំណើរ ពួកយោធាតាមសម្លឹងមើលនាងជានិច្ច។

**សុវណ្ណា/អ្នកជិតខាង ~**
ឪពុកម្តាយរបស់ ជា ខិតខំការពារនាងខ្លាំងណាស់។
ពួកគេបានយកភក់មកប៉ាតលើមុខនាង ដើម្បីបិតបាំង
សម្រស់របស់នាង។
នាងតែងតែយកក្រមាមកទទូរក្បាលជានិច្ច។

**ធារី/អ្នកជិតខាង ~**
នៅពេលដែលនាងធ្វើដំណើរ ពួកយោធាតាមសម្លឹងមើលនាងជានិច្ច។

**សុវណ្ណា/អ្នកជិតខាង ~**
នាយប់មួយ ក្នុងខែមីនា ឆ្នាំ១៩៧៦ យោធា ៣នាក់ បានមក
ខ្ទមដែលគ្រួសារ ដា រស់នៅ។

**ធារី/អ្នកជិតខាង ~**
ពួកគេនិយាយថា អង្គការត្រូវការស្មើ ដា ឲ្យទៅកាច់ពោត។

**សុវណ្ណា/អ្នកជិតខាង ~**
ម្តាយរបស់ ដា ឱបដៃ ដា ជាប់។
គាត់យំសោក «មិត្តបងអើយមិត្តបង យកខ្ញុំទៅជំនួសវិញទៅ
ខ្ញុំអាចធ្វើការបានលឿនជាង ហើយអាចបេះពោតបានច្រើនជាង
កូនស្រីខ្ញុំ»។
ឪពុក ដា លត់ជង្គង់អង្វរ « មិត្តបងយកខ្ញុំទៅវិញទៅ ខ្ញុំមានកម្លាំង
ខ្លាំងជាង។ ខ្ញុំអាចធ្វើការជូនមិត្តបងមួយយប់ទល់ភ្លឺក៏បានដែរ»។

**ធារី/អ្នកជិតខាង ~**
យោធានោះនិយាយថា «មិនបានទេ។ អង្គការត្រូវការតែ ដា ប៉ុណ្ណោះ។
គ្មានអ្វីអាចតវ៉ាបានឡើយ។
តវ៉ាជាមួយអង្គការ គឺគ្មានប្រយោជន៍នោះទេ។
អង្គការប្រាប់ឲ្យធ្វើអ្វី គឺយើងត្រូវតែធ្វើ។

**សុវណ្ណា/អ្នកជិតខាង ~**
ពួកយោធាចាប់យក ដា ទៅក្នុងព្រៃ។ ដា ងាកក្រោយសម្លឹងមើល
ឪពុកម្តាយរបស់ខ្លួនរហូតផុតកន្ទុយភ្នែក។

នៅក្នុងរាត្រីងងឹត ម្តាយរបស់ ដា យំសោកដូចអកព្រាត់កូនអញ្ចឹង។
ពិតដូចសម្តីពួកយោធាបានសន្យាមែន ពួកគេបានបញ្ជូន ដា មកឲ្យ
ឪពុកម្តាយនាងវិញ នៅពេលព្រឹកស្អែក។ ប៉ុន្តែនាងលែងជា ដា ដែល
ស្រស់ស្អាត និងញញឹមរស់រាយរាក់ទាក់ដូចកាលពីមុនទៀតហើយ។
មុខនាងឡើងហើម ស្មាធ្លាក់ចុះ ដៃទាំងទ្វេសំយុងហាក់គ្មានជីវិត។
ចាប់តាំងពីពេលនោះមក ដា ឈប់និយាយស្តីជារៀងរហូត។
នាងបោះជំហានដើរដូចមនុស្សគ្មានវិញ្ញាណ។
នាងតែងតែឱនមុខចុះជានិច្ច។

គ្មាននរណាមកជិត ដា ឡើយ។
គ្មាននរណានិយាយជាមួយ ដា ឡើយ។
មនុស្សម្នានាំគ្នាគេចមុខចេញ នៅពេលដែលនាងដើរកាត់។

**សុខលី/អ្នកជិតខាង ~**
កាលនេះ ខ្ញុំក៏នៅទីនោះដែរ គឺនៅការដ្ឋានជាមួយនឹងនាង។
កាលពីឆ្នាំ១៩៧៦ ខ្ញុំតែងតែងាកមុខចេញពី ដា ដែរ
នៅពេលដែលនាងដើរកាត់ម្តងៗ។
ជួនកាល ដា បានដើរតម្រង់ទៅកាន់ហ្វូងមនុស្សដែលកំពុងរង់ចាំ
ទទួលរបបអាហារ។ ធ្វើដូចជា ដា គ្មានរូបរាងអញ្ចឹង។
ហ្វូងមនុស្សទាំងនោះ ប្រញាប់ប្រញាល់គេចចេញពីនាង ហើយមិន
ក្រឡេកមើលទៅនាងឡើយ។ ខ្ញុំក៏អញ្ចឹងដែរ។

យើងបានធ្វើឲ្យ ដា ក្លាយជាមនុស្សបែបហ្នឹង។

ឥឡូវនេះ៣០ឆ្នាំក្រោយមក ដា រស់នៅក្នុងភូមិរបស់ខ្ញុំ។
នាងគឺជាស្ត្រីស្ងៀមស្ងាត់ម្នាក់។
គ្មាននរណាមកជិត ដា ឡើយ។
គ្មាននរណានិយាយរក ដា ឡើយ។
មនុស្សម្នាងាកមុខចេញ ពេលដែល ដា ដើរកាត់។

រាល់ពេលឲ្យតែខ្ញុំឃើញគាត់ បេះដូងខ្ញុំតែងតែលោតញាប់ខុសធម្មតា។
ខ្ញុំមានអារម្មណ៍ខុសឆ្គង គឺខុសឆ្គងធ្ងន់មែនទែន។
ខ្ញុំនិយាយទៅកាន់ខ្លួនឯង៖ «កាលនោះ ខ្ញុំគ្រាន់តែជាក្មេងស្រីតូច
ម្នាក់។ ខ្ញុំមិនអាចជួយអ្វីបាននោះទេ។
ខ្ញុំធ្វើតាមតែចាស់ៗ ប្រាប់។ ខ្ញុំគ្រាន់តែជាក្មេងស្រីតូចម្នាក់ប៉ុណ្ណោះ។
ខ្ញុំនិយាយប្រាប់ខ្លួនឯងថា៖ «ខ្ញុំក្បត់ ដា។ ខ្ញុំបានទុកឲ្យនាងនៅ
ភិតភ័យតែឯង។ ខ្ញុំជាមនុស្សកំសាក»។

ថ្ងៃនេះខ្ញុំឃើញ ដា។ បេះដូងខ្ញុំលោតញាប់ខ្លាំងណាស់។
ខ្ញុំចាប់ផ្តើមបែកញើស។ តែខ្ញុំត្រូវតាំងចិត្ត។ ខ្ញុំមិនអាចទ្រាំទ្រ
នឹងអារម្មណ៍ខុសឆ្គងបែបនេះទៀតទេ។



# អត់ទោស
## ឲ្យខ្ញុំផងបានទេ?

ខ្ញុំក៏បោះជំហានយឺតៗសំដៅទៅរក ដា។ មួយជំហាន ហើយមួយ
ជំហានទៀត។ «ដា.... អត់ទោសឲ្យខ្ញុំផងបានទេ....សូមមក
ជាមួយខ្ញុំ យើងអង្គុយហូបតែ ហើយជជែកគ្នាលេងបន្តិចបានទេ?»
ដា... ដា....ដា មិនបានក្រឡេកមើលមុខខ្ញុំទេ ហើយក៏អត់និយាយ
អ្វីដែរ។ ខ្ញុំប្រហែលជានិយាយយឺតពេលបន្តិចទៅហើយ។

ប៉ុន្តែថ្ងៃស្អែក ខ្ញុំនឹងព្យាយាមម្តងទៀត។

**♪ ចម្រៀង**

(វុត្ថា, សុវណ្ណា, ធារី និង សុខលី)

**អ៊ូ អឿ — របាំទេពកញ្ញា**

*ឱ!ទេពកញ្ញា ឥតបីហ្មងសៅគន់មើលយូរទៅ*
*ជាប់នៅនេត្រា។*



# ឈុតទី៧

**វុត្ថា ~**
នេះគឺជារឿងរបស់ក្មេងប្រុស និងក្មេងស្រីដែល
ធ្លាប់ជាមិត្តជិតស្និទ្ធនឹងគ្នា

អ្នកគឺលោក សារុន។
អ្នកមានអាយុ៤៩ឆ្នាំ។
អ្នកមិនជឿជាក់អ្នកណាទាំងអស់។

អ្នកគឺអ្នកស្រី សុភា។
អ្នកមានអាយុ៤៩ឆ្នាំ។
អ្នកជាម្តាយដែលចេះថ្នាក់ថ្នមម្នាក់។

**ស៊ីណា/សុភា ~**
អេ...ខ្ញុំដូចជាធ្លាប់ស្គាល់ពូឯង?

**ធារី/សារុន ~**
អត់ទេ...

**ស៊ីណា/សុភា ~**
ដូចជាប្រហែលមុខនៅឯណាទេនៀក់!

**ធារី/សារុន ~**
ទេ...ខ្ញុំមិនដែលជួបមីងឯងទេ....

**ស៊ីណា/សុភា ~**
កាលណោះយើងជិះឡានឆ្លងកាន់ភ្នំពេញជាមួយគ្នា...
ហើយបន្ទាប់មកយើងថែមទាំងនៅក្នុងអង្គភាពជាមួយគ្នា
១ខែទៀតផង....ចាំនៅ?

**ធារី/សារុន ~**
អត់ទេ....ខ្ញុំមិនដែលស្គាល់មីងឯងទេ។
តើមីងឯងចង់យ៉ាងម៉េចហ្នឹង?

**ស៊ីណា/សុភា ~**
សប្បាយចិត្តមែនទែនដែលបានជួបពូឯងម្តងទៀត។ មុខពូឯង
កាលណោះ មើលទៅគួរឲ្យចង់សើច ហើយញញឹមស្រស់ទៀត។

**ធារី/សារុន ~**
មីងឯងឆ្កួតទេអ្ហែ?

**ស៊ីណា/សុភា ~**
ម៉េចក៏ពូនិយាយអញ្ចឹង? យើងធ្លាប់ច្រៀងរាំជាមួយគ្នាសប្បាយ
សឹងអី។ កាលណោះ ពូឯងរាំស្អាតជាងគេ។

**ធារី/សារុន ~**
មែនអី?

**ស៊ីណា/សុភា ~**
មែនណា!...ឥឡូវចាំមើលចុះ ពូឯងច្បាស់ជានឹកឃើញមិនខាន។
ពួកយើងដើរឡើងទៅមុខ ហើយឈរពីមុខហ្វូងមនុស្ស។
ពួកយើងកំពុងស្លៀកពាក់ខោអាវពណ៌ខ្មៅយ៉ាងថ្មីស្រស់ស្អាតជាមួយ
នឹងក្រមាពណ៌ក្រហមភ្លឺចិញ្ចាច ចងនៅនឹងចង្កេះរបស់ពួកយើង។
ពួកយើងពាក់បូរពណ៌ក្រហម និងផ្កាពណ៌ក្រហមដែលធ្វើពីចំបើង
ជ្រលក់ល័ក្តនៅលើថ្ងាសរបស់យើង។

## ♪ ចម្រៀង

(ច្រៀងទាំងអស់គ្នា។ វុត្ថា ពោល)

## ចម្រៀងអង្គការ

*យើងខ្ញុំកុមារ ស្រឡាញ់អង្គការឥតមានព្រំដែន
ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន
រីករាយអស្ចារ្យ។*

*មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា
រស់ដូចសត្វធាតុ កំព្រាខ្លោចផ្សា អាក្បត់មហា
គ្មាននឹកនាដល់។*

*ស្បែកដណ្ដប់ធ្មឹង ស្គមស្គាំងកំព្រឹង
មហាសែនកង្វង់ យប់ដេកនឹកនា
ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់
ដើរសុំទានគេ។*

*ឥឡូវយើងខ្ញុំ អង្គការឧត្ដម ឧបត្ថម្ភគ្រប់គ្នា
បំប៉នសុខភាព កម្លាំងក្លាំងក្លា ឲ្យក្លាយទៅជា
សមូហភាព។*

*ពួកយើងគឺជាកុមាររបស់អង្គការ។
ពួកយើងគ្មានខ្លាចអីទាំងអស់។ ពួកយើងគឺជា
អនាគត។ យើងរៀនប្រយុទ្ធ។
ហើយនេះជាកាំភ្លើង។ កាំភ្លើងស្រួលបាញ់។
កូនក្មេងក៏អាចបាញ់បានដែរ។
(ថាឡើងវិញដដែលៗ)*

**ធារី/សារុន ~**
ដឹងទេ ខ្ញុំចូលចិត្តកាំភ្លើង។

**ស៊ីណា/សុភា ~**
ខ្ញុំចូលចិត្តត្រង់ថា ប្រុស ហើយនឹងស្រី គេចាត់ទុកស្មើគ្នា។
ខ្ញុំចូលចិត្តការច្រៀងរាំ។ ហើយខ្ញុំចូលចិត្តការរស់នៅជុំគ្នា
ដូចគ្រួសារមួយអញ្ចឹង។

**ធារី/សារុន ~**
ត្រូវហើយ...កាលហ្នឹងសប្បាយមែនទែន។
យើងគ្រោងថានឹងធ្វើឲ្យមានពិភពមួយដែលកាន់តែល្អ។
កាលណោះអង្គការនិយាយថា៖ យើងគឺជាអនាគត យើងគឺជាកុមារ
របស់អង្គការ។ ចាប់ពីនេះទៅ អង្គការគឺជាគ្រួសារពិតប្រាកដ និង
ជាគ្រួសាររបស់យើងតែមួយគត់។
ដើម្បីឲ្យបដិវត្តន៍ទទួលបានជោគជ័យ អង្គការពឹងលើ
យើងទាំងស្រុងហើយ។ ពួកយើងសំខាន់ណាស់។
ហើយការងារនេះក៏មិនមែនលេងសើចដែរ។
គេប្រាប់យើងថា ត្រូវតែឃាមឲ្យបានហ្មត់ចត់។
មានសត្រូវច្រើនណាស់។
កុំទុកចិត្តអ្នកទីក្រុងដៃទន់ៗអស់នោះឲ្យសោះ។
ចាប់ពីពេលនេះទៅពួកអ្នកទីក្រុងអស់នោះនឹងត្រូវធ្វើការងារ
ជាក់ស្ដែង និងស្មោះត្រង់ ដើម្បីធ្វើឲ្យប្រទេសមហាលោតផ្លោះ
មហាអស្ចារ្យរបស់យើង សម្បូរទៅដោយវាលស្រែ និងឲ្យអ្នកគ្រប់
គ្នាមានហូបចុកគ្រប់គ្រាន់។
បើពួកអស់នោះខ្ជិល ឬក៏ឈឺ បានន័យថា ពួកវាគ្មានប្រយោជន៍អីទេ
ហើយអង្គការត្រូវតែកំចាត់ពួកវាចោល។
គេថាកង់ប្រវត្តិសាស្ត្រកំពុងតែវិល។ អ្នកណាហ៊ានលូកជើងដាច់ជើង។
នេះគឺជារឿងសំខាន់ណាស់។ យើងគឺជាកង់ប្រវត្តិសាស្ត្រ។

**ស៊ីណា/សុភា ~**
ពូឯងនៅជឿសម្ដីអស់ហ្នឹងដែរ?

**ធារី/សារុន ~**
កាលណោះ ខ្ញុំជឿតើស៍...ខ្ញុំមិនដែលមានអារម្មណ៍ថា ខ្លួនខ្ញុំមាន
សារៈសំខាន់ដូចកាលណោះទេ។ ខ្ញុំពិតជាជឿសម្ដីគេនិយាយមែន។



**ស៊ីណា/សុភា ~**
ប៉ុន្តែកាលនោះ យើងធ្វើរឿងអាក្រក់ច្រើនណាស់។

**ធារី/សារុន ~**
តែកាលណោះគឺជាសង្គ្រាម។ វាគឺជាបដិវត្តន៍។ បើមិនធ្វើតាមបញ្ជា
គឺប្រាកដជាត្រូវស្លាប់។ តើនរណាចង់ស្លាប់ទៅ?

**ស៊ីណា/សុភា ~**
ម៉េចបានពូឯងខឹងអីខ្លាំងម៉េះ?

**ធារី/សុភី ~**
ខ្ញុំអត់ខឹងទេ។ ខ្ញុំគ្រាន់តែឈឺក្បាល។ ខ្ញុំឈឺក្បាលចង់បែកហើយ។

# សុបិន្តអាក្រក់

**វុត្ថា ~**
*នេះគឺឆ្នាំ១៩៧៥។
អ្នកជាក្មេងប្រុសម្នាក់អាយុ១៥ឆ្នាំ។
អ្នកសម្លឹងឃើញក្មេងស្រីម្នាក់កំពុងរើសផ្លែឈើមួយផ្លែដែលជ្រុះ
ពីដើម។ ក្មេងស្រីតូចនោះ បំរុងដាក់ផ្លែឈើចូលទៅក្នុងមាត់ ប៉ុន្តែ
អ្នកដែលមានអាយុ១៥ឆ្នាំនោះ បានវាយកុមារីម្នាក់នោះរហូតដល់
ស្លាប់។ ហើយអ្នកនិយាយថា៖ «ផ្លែឈើទាំងអស់ជារបស់អង្គការ។
ឯងលួចរបស់អង្គការ។ ឯងគឺជាខ្មាំង»។*

**ស៊ីណា/សុភា ~**
មើលទៅមុខពូ ដូចជាស្លេកស្លាំងដល់ហើយនែក៎។
នេះ! ហូបទឹកបន្តិចទៅពូ!
បើមិនអញ្ចឹងទេ យើងទៅនិយាយគ្នាលេងបន្តិចទៅពូ។
ហើយការរស់នៅរបស់ពូ យ៉ាងម៉េចហើយពូ?
ពូរៀបការហើយនៅ?
ហើយពូធ្វើការអ្វីដែរ?

**ធារី/សារុន ~**
ខ្ញុំធ្វើការអី គ្មានអីធំដុំទេ។
ខ្ញុំលក់សៀវភៅនៅតាមផ្លូវហ្នឹង។

**ស៊ីណា/សុភា ~**
សៀវភៅ! សៀវភៅរបៀបម៉េចទៅ?

**ធារី/សារុន ~**
សៀវភៅដែលគេនិយាយកាលពីសម័យអាពតនោះ។

**ស៊ីណា/សុភា ~**
ចំណែកខ្ញុំ! ខ្ញុំមេម៉ាយកូន៣ហើយ។
ខ្ញុំលក់ត្រីបែក លក់ម្ទេស លក់ទឹកសុទ្ធ។
ល្មមឲ្យកូនខ្ញុំទៅរៀន។
កូនខ្ញុំឥឡូវ វាចេះអក្សរ។ វាគ្រាន់បើជាងខ្ញុំ។
ខ្ញុំអត់ចេះអក្សរ។ បើចង់រៀនក៏រៀនមិនកើតដែរ។
តែបើខ្ញុំចេះអក្សរវិញ ខ្ញុំប្រាកដជាអានសៀវភៅដែលពូ
លក់ហ្នឹងហើយ។
ចុះរាល់ថ្ងៃ ពូ អានសៀវភៅអស់នោះហើយនៅ?

**ធារី/សារុន ~**
អ្នកណាទៅចង់អានសៀវភៅអស់ហ្នឹងទៅ។
សៀវភៅទាំងអស់ហ្នឹងសម្រាប់តែភ្ញៀវបរទេសដែលគេចូលចិត្ត។
១ថ្ងៃ ខ្ញុំលក់បាន១ក្បាល គឺខ្ញុំមានបាយហូបហើយ។
សៀវភៅសម្រាប់ខ្ញុំ គឺមានប្រយោជន៍តែប៉ុណ្ណឹង។
ចុះមីងឯងសួររឿងហ្នឹងធ្វើអី?

**ស៊ីណា/សុភា ~**
ខ្ញុំគ្រាន់តែសួរចង់ដឹងហ្នឹងណា៎។
ពូប្រាប់ខ្ញុំបានទេ! ហេតុអីបានជាពូបាត់បង់ស្នាមញញឹមដែល
សប្បាយរីករាយដូចកាលពីមុនអញ្ចឹង?
ម៉េចបានជាពូនៅមានជីវិតរហូតមកដល់សព្វថ្ងៃ?
ហើយឥឡូវ! ម៉េចពូអត់មាននិយាយអីសោះអញ្ចឹង?

# សុបិន្តអាក្រក់

**ធារី/សារុន ~**
ខ្ញុំឈឺក្បាលណាស់! ខ្ញុំឈឺក្បាលស្ទើរបែកហើយ។

**វុត្ថា ~**
*នេះគឺជាឆ្នាំ១៩៧៦។*
*យោធា៣នាក់ បានមកដល់ផ្ទះ ជា។*
*អ្នកក៏ជាមនុស្សម្នាក់ក្នុងចំណោមនោះដែរ។*
*អ្នកមានអាយុ១៦ឆ្នាំ។*
*យោធាទាំង៣នាក់នោះ អូស ជា ចូលព្រៃ។*
*ជា ស្រែក។ យោធាទាំង៣នាក់វំលោភ ជា។*
*អ្នកក៏ជាមនុស្សម្នាក់ក្នុងចំណោមនោះដែរ។*

**ធារី/សារុន ~**
ខ្ញុំធ្វើដើម្បីអង្គការទេ។ យើងនឹងបង្កើតពិភពលោកមួយ
ឲ្យប្រសើរជាងនេះទេ។

**ស៊ីណា/សុភា ~**
ត្រូវហើយ! កាលនោះគេនិយាយអញ្ចឹងមែន។
ប៉ុន្តែយើងបានធ្វើអំពើអាក្រក់ច្រើនណាស់។
កាលនោះ ខ្ញុំភ័យទាំងយប់ទាំងថ្ងៃ។
អញ្ចឹងហើយបានជាខ្ញុំធ្វើអំពើអាក្រក់ច្រើនណាស់ ដើម្បីឲ្យពួកគេ
ហ្នឹងបានសប្បាយចិត្ត។

**ធារី/សារុន ~**
ចុះមីងឯងនិយាយថារឿងអាក្រក់ហ្នឹង ចង់មានន័យថាយ៉ាងម៉េច?
យើងក៏ត្រូវលះបង់ខ្លួនឯងដែរ។
ខ្ញុំធ្វើតាមតែបញ្ជាគេហ្នឹង វាពិបាកណាស់ទៅហើយ។
នៅពេលដែលខ្ញុំត្រឡប់មកផ្ទះខ្ញុំវិញ ទើបខ្ញុំដឹងថាពុកម៉ែរបស់ខ្ញុំ
ត្រូវអ្នកភូមិដែលខឹងសម្បាជាមួយនឹងខ្ញុំ សម្លាប់ហើយអ្នកជិតខាង
បានយកពូថៅមកវាយក្បាលខ្ញុំទៀត គឺដោយសារតែខ្ញុំជាយោធា
របស់អាពត។ ប្អូនប្រុសរបស់ខ្ញុំនៅរស់រហូតដល់សព្វថ្ងៃ តែវាអត់
និយាយរកខ្ញុំទេ។ ហេតុអីទៅ? តើវាដឹងអីខ្លះទៅ? កាលនោះវា
មានអាយុទើបតែ២ឆ្នាំប៉ុណ្ណោះ។ ត្រូវហើយ! ប្រហែលកាលនោះ
ពួកគេរស់នៅលំបាក ប៉ុន្តែឥឡូវនេះ ក៏មិនស្រួលប៉ុន្មានដែរ។
ពួកយើងដូចជាស្លាប់ទាំងរស់អញ្ចឹង។

**ស៊ីណា/សុភា ~**
ឲ្យខ្ញុំនិយាយរឿងមួយបានទេ? រឿងនេះសំខាន់ណាស់។
ថ្ងៃមួយមានកើតរឿងរ៉ាវយ៉ាងច្រើន
កាលនោះ នៅឆ្នាំ១៩៧៧។ ខ្ញុំមានអាយុ១៥ឆ្នាំ។
ខ្ញុំបានក្បត់ជាមួយមីងម្នាក់។ ខ្ញុំបានឮគាត់ច្រៀងចម្រៀងបំពេកូន
គាត់កាលពីសម័យមុន។ គេក៏យកគាត់ទៅភ្លាម។ ហើយបាត់រហូត។
នៅថ្ងៃដដែលនោះ កងកម្លាំងយើងបាននាំគ្នាទៅវាយ
ព្រះពុទ្ធរូបនៅក្នុងវត្ត។
យប់នោះ ខ្ញុំយល់សប្តិអាក្រក់។ ខ្ញុំបានឮសម្លេងមួយស្រែកមករកខ្ញុំ។

> **♪ ចម្រៀង** (សុខលី)
>
> *កុំភ្លេចរឿងអាប ពេលយប់អាបដេក*
> *ចេញពីខ្លួនប្រាណ ក្បាលហោះលឿនណាស់*
> *ជាមួយពោះវៀន លិឍខ្ទុះលិឍឈាម*
> *ស៊ីសាច់មនុស្សស្លាប់។*

**ស៊ីណា/សុភា ~**
ពេលដែលខ្ញុំដឹងខ្លួនឡើង ខ្ញុំបានដឹងថាសុបិន្តនោះបានប្រាប់ខ្ញុំថា
ខ្ញុំបានជាប់ជំពាក់ជាមួយរឿងកម្មអកុសលនោះហើយ។
តែឥឡូវនេះ ទើបខ្ញុំដឹងថា សុបិន្តអាក្រក់កាលពីយប់នោះបាន
ជួយសង្គ្រោះព្រលឹងខ្ញុំខ្លះ។

**ធារី/សារុន ~**
ឈប់និយាយទៅ។ ឈប់ទៅ! ខ្ញុំមិនចង់ឮទេ។
ខ្ញុំលែងចង់ឮអ្វីទាំងអស់។ ខ្ញុំមិនចង់ឈឺក្បាលទៀតទេ។

**ស៊ីណា/សុភា ~**
អត់ទេ...ខ្ញុំឈប់មិនបានទេ។
ខ្ញុំត្រូវតែសួរសំណួរពូមួយ ហើយខ្ញុំចង់ឲ្យពូឯងស្តាប់។
ខ្ញុំដឹងអំពីពុទ្ធិដីកាថា៖ កុំចូលរួមក្នុងការប្រយុទ្ធ ប៉ុន្តែកុំលាក់បាំងពីវា។
អញ្ចឹងហើយបានជាខ្ញុំទៅទួលស្លែងជារៀងរាល់ឆ្នាំ គឺដោយសារតែខ្ញុំ
មិនចង់លាក់បាំងពីអតីតកាលរបស់ខ្ញុំ។ ថ្ងៃស្អែកនេះគឺដល់ថ្ងៃ
ដែលខ្ញុំត្រូវទៅទៀតហើយ។
ប៉ុន្តែមុនពេលដែលខ្ញុំទៅ ខ្ញុំមានអារម្មណ៍ភ័យខ្លាច។
ខ្ញុំពិតជាភ័យខ្លាចមែន។
នៅពេលទៅដល់ទួលស្លែង ខ្ញុំបានឃើញជនរងគ្រោះជាច្រើន
ជាពិសេសគឺក្មេងតូចៗ។
ខ្ញុំគិតថា ខ្ញុំទេដែលគួរស្លាប់ជំនួសពួកគេ។ ខ្ញុំមានអារម្មណ៍កំសត់
ណាស់។ ខ្ញុំបានសែនសំណែនឲ្យពួកគេ។ សុំឲ្យព្រលឹងពួកគេនោះ
អភ័យទោសឲ្យខ្ញុំ ថ្ងៃបន្ទាប់មក ខ្ញុំមានអារម្មណ៍ក្រៀមក្រំ។ ប៉ុន្តែខ្ញុំ
លែងមានសុបិន្តអាក្រក់ទៀតហើយ។
ស្អែកពូចង់ទៅជាមួយខ្ញុំទេ?
ពូទៅៗ ប្រហែលជាមានអារម្មណ៍បាត់ឈឺក្បាលណា!
ពូ! ពូហ៊ានទៅជាមួយខ្ញុំអត់?

**ធារី/សារុន ~**
ខ្ញុំប្រហែលជាទៅ។

**ស៊ីណា/សុភា ~**
អញ្ចឹងម៉ោង១១ ខ្ញុំមកកន្លែងនេះ។

នៅពេលដែលខ្ញុំត្រឡប់មកផ្ទះវិញ ទើបខ្ញុំដឹងថា
## ពុកម៉ែរបស់ខ្ញុំត្រូវអ្នកភូមិ
## ដែលខឹងសម្បាជាមួយខ្ញុំសម្លាប់
ហើយអ្នកជិតខាងបានយកពូថៅមកវាយក្បាលខ្ញុំទៀត
ដោយសារតែខ្ញុំជាយោធារបស់អាពត។



# ឈុតទី ៨

(តួសម្តែងប្រុស (តួសម្តែងស្រី) ម្នាក់កំពុងអង្គុយក្នុងពេលសម្តែងនៅចំពោះមុខទស្សនិកជន។ គាត់កើតក្រោយអំពើប្រល័យពូជសាសន៍បន្តិច។ ភ្លាមៗបន្ទាប់ពីពាក្យសម្តីចុងក្រោយរបស់ ធារី ដែលនិយាយថា "ខ្ញុំប្រហែលជាទៅ" គាត់លោតឡើងលើឆាក ហើយចាប់ផ្តើមឈុតចុងក្រោយថ្មីមួយ ដែលគឺជាការពិភាក្សារវាងមនុស្សពីរជំនាន់ខុសគ្នា។)

**ភារិទ្ធ ~**
ប្រហែលជា តែងតែ ប្រហែលជា?
ហេតុអ្វីត្រូវស្ទាក់ស្ទើរ!
សម្រេចចិត្តទៅ,
តើត្រូវទៅ ឬនៅ?
ឈប់និយាយពាក្យ ប្រហែលជា ទៀតទៅ!

**សុវណ្ណា ~**
ឯងទេដែលត្រូវឈប់!
ចេញទៅ!
ឯងជានរណា?

**សុខលី ~**
តើឯងមកធ្វើអីនៅទីនេះ?
អីក៏ហ៊ានម្លេះ!

**ធារី ~**
នេះគឺជាឆាករបស់យើង។
នេះគឺជាការសម្តែងរបស់យើង។

**ភារិទ្ធ ~**
ខ្ញុំឈ្មោះ សំណាង។
ខ្ញុំគឺជាកូនខ្មែរ។
ខ្ញុំនៅក្មេងនៅឡើយ។
ខ្ញុំគឺជាខ្មែរដែលមានវ័យក្មេងម្នាក់។
ខ្ញុំបានស្តាប់ឮពាក្យសម្តីរបស់ពូមីង ហើយខ្ញុំមានសំណួរជាច្រើនដែលចង់សួរ។
ខ្ញុំបានមើលការសម្តែងរបស់ពូមីង។ ខ្ញុំហាក់ដូចជាមានការភ័ន្តច្រឡំ។
ហេតុអ្វីសុទ្ធតែជាការអាម៉ាស់?
អាម៉ាស់ដោយសារអ្វី ឬដោយសារនរណា?
ហេតុអ្វីត្រូវខ្លាច?
ខ្លាចដោយសារអ្វី ឬដោយសារនរណា?
ហេតុអ្វីជាកំហុសដែលគ្មានទីបញ្ចប់?
ហេតុអ្វីស្ងៀមស្ងាត់?
ហេតុអ្វីវាមានពណ៌ខ្មៅ ដូចមេឃដែលហៀបនឹងធ្លាក់ភ្លៀង?
ហេតុអ្វីបានជាស្មុគស្មាញខ្លាំងដូចជាការស្វែងរកម្ជុលក្នុងបាតសមុទ្រ?

**សុវណ្ណា ~**
ឈប់និយាយទៅ!
នេះមិនមែនជាអំពើប្រល័យពូជសាសន៍របស់ឯងតែម្នាក់នោះទេ។

**ភារិទ្ធ ~**
ទេ! ខ្ញុំមិនឈប់និយាយទេ។
ពូមីងក៏ជាឪពុកម្តាយរបស់ខ្ញុំ (មនុស្សជំនាន់មុន)។
ដូច្នេះខ្ញុំក៏ជាផ្នែកមួយនៃអំពើប្រល័យពូជសាសន៍នេះដែរ

ហើយខ្ញុំត្រូវតែដឹង។
តើមានរឿងអ្វីកើតឡើង?
ខ្ញុំត្រូវការដឹង។
ប្រាប់ខ្ញុំមក។
ខ្ញុំត្រូវការដឹងឥឡូវនេះ។
តើមានរឿងអ្វីកើតឡើងខ្លះ? តើមនុស្សគ្រប់គ្នាសុទ្ធតែវង្វេងវង្វាន់ឬ?

**ស៊ីណា ~**
ឯងមិនដឹងទេ។
ឯងមិនបានកើតចំពេលដែលយើងទាំងអស់គ្នាឈឺចាប់នោះទេ។

**ភារិទ្ធ ~**
វាជាការពិត។
ប៉ុន្តែយើងរស់នៅក្នុងប្រទេសតែមួយដូចគ្នា។
ជាប្រទេសដែលមានប្រជាជន១៥លាននាក់រស់នៅសព្វថ្ងៃ
រួមទាំងក្មេងៗដែលជាកូនៗរបស់ជនរងគ្រោះ និងកម្មាភិបាល
ខ្មែរក្រហមដែរ។
បាទ! យើងដកដង្ហើមចូលដូចគ្នា។
យើងផឹកទឹកដូចគ្នា។
ខ្ញុំគោរពពូមីង និងរឿងរ៉ាវពីអតីតកាលរបស់ពូមីង។
ប៉ុន្តែខ្ញុំមិនចង់ធ្លាក់ចូលទៅក្នុងការចងចាំដ៏អាក្រក់របស់ពូមីងទេ។
អំពើប្រល័យពូជសាសន៍ គឺជាអត្តសញ្ញាណរបស់យើង។

## ♪ ចម្រៀង

*ប្រសិនបើទឹកនៅក្នុងអណ្តូងនៅតែថ្លា*
*សូមមេត្តាកុំព្យាយាមធ្វើឲ្យល្អក់។*
*សូមកុំពង្រាយសម្រាមទៅក្នុងទឹក*
*និងកុំចុះងូតទៅក្នុងទឹក។*

**ភារិទ្ធ ~**
ខ្ញុំត្រូវដឹងពីអ្វីដែលធ្វើឲ្យពូមីងលែងនិយាយស្តី និង
យំដោយគ្មានទឹកភ្នែក។
ខ្ញុំចង់រៀន ចង់ដឹងថាខ្ញុំមកពីទីកន្លែងណា។

**សុខលី ~**
ឯងមិនអាចយល់ពីអ្វីដែលយើងបានឆ្លងកាត់ឡើយ។
ឈប់និយាយទៅ។ ឯងគ្មានសិទ្ធិផ្លាស់ប្តូរជីវិតខ្ញុំ តាមរយៈ
ការចង់ដឹងចង់ឃើញរបស់ឯងបានទេ។
យើងកំពុងឈឺចាប់ចំពោះអតីតកាល ដែលជារឿងរ៉ាវដ៏រន្ធត់
ពិបាកនឹងរ៉ាយរ៉ាប់។
យើងឈឺចាប់ចំពោះមនុស្សអាក្រក់ដែលបំផ្លាញជីវិតរបស់យើង។

**ធារី ~**
ហើយយើងក៏មិនបានដឹងពីហេតុអ្វីឡើយ។
តើយើងបានប្រព្រឹត្តកំហុសអ្វីខ្លះ?
តើយើងអាក្រក់ពីធម្មជាតិមែនទេ?
តើជនដៃដល់ទាំងអស់ សុទ្ធតែជាមនុស្សអាក្រក់ពីធម្មជាតិមែនទេ?
ឪពុកដូចកូនប្រុស ហើយកូនប្រុសក៏ដូចឪពុក? ម្តាយដូច
កូនស្រី ហើយកូនស្រីក៏ដូចម្តាយដែរ?

**ភារិទ្ធ ~**
ខ្ញុំចង់ប្រាប់ពូមីងពីរឿងរ៉ាវមួយ ដែលជារឿងពិត។
រឿងរ៉ាវរបស់ខ្ញុំ
សូមស្តាប់!
ក្នុងនាមក្មេងម្នាក់ យើងតែងមានញាតិជិតខាងថ្មី។ អ្នកជិតខាងនោះ
មានកូនប្រុសម្នាក់ដែលមានអាយុស្របាលខ្ញុំ។
ខ្ញុំគិតថា អស្ចារ្យណាស់ គេជាមិត្តថ្មីម្នាក់ ហើយខ្ញុំចង់លេង
ជាមួយមិត្តម្នាក់នោះ។
ប៉ុន្តែ ឪពុកខ្ញុំបានចាប់កៀកកខ្ញុំជាប់ ហើយស្រែកដាក់ខ្ញុំជាពាក្យសម្តី
ដែលខ្ញុំមិនដែលបានឮទាល់តែសោះពីមុនមក ថា "តើឯងមិន
ធ្លាប់បានលេងជាមួយកូនប្រុសរបស់គ្រួសារនោះពីមុនមកទេឬ?
កុំថាឡើយនិយាយ សូម្បីតែមើលក៏មិនបានដែរ»។
ខ្ញុំសួរថា ហេតុអ្វី?
ពុកឆ្លើយថា «ឪពុករបស់ក្មេងនោះគឺជាឃាតករម្នាក់»។
ពុកបន្តថា "ឪពុកដូចកូន កូនក៏ដូចឪពុកដែរ»។



ឈាមអាក្រក់ គឺនៅតែអាក្រក់អញ្ចឹង។
អាក្រក់ជារៀងរហូត។"
ស្តាប់ទៅគួរឲ្យរន្ធត់ណាស់ ប៉ុន្តែខ្ញុំនៅក្មេងពេក ខ្ញុំមិនយល់ ហើយខ្ញុំ
មិនហ៊ានសួរពីរឿងនេះទេ។

ប៉ុន្តែឥឡូវខ្ញុំធំហើយ។
ឪពុកខ្ញុំក៏បានស្លាប់ទៅបាត់។
នេះជាមូលហេតុដែលខ្ញុំមកជួបពូមីង ដើម្បីចង់បានចម្លើយពីពូមីង។
ប្រាប់ខ្ញុំមក តើមានរឿងអ្វីកើតឡើងខ្លះ?
ហេតុអ្វីបានជាមិនទុកចិត្ត?
ហេតុអ្វីបានជាស្អប់?
ហេតុអ្វីទៅ?
ប្រាប់ខ្ញុំមក តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីដាក់ទោសឲ្យធ្ងន់ធ្ងរបំផុត?

**ស៊ីណា ~**
ប្រហែលជាកម្មរបស់យើងទេ។

**ភារិទ្ធ ~**
តើជាកម្មរបស់នរណា?

**ស៊ីណា ~**
ជាកម្មដ៏អាក្រក់របស់យើង។ វាសនារបស់ប្រទេសកម្ពុជា។
ប្រហែលមកពីយើងសមនឹងទទួលបានការឈឺចាប់ ដោយសារ
តែផលកម្មអាក្រក់នេះ។

**ភារិទ្ធ ~**
ពួកយើង? តើពួកយើងជានរណា?

**សុខលី ~**
ពួកយើង គឺជាប្រជាជនកម្ពុជា។

**ភារិទ្ធ ~**
តើពូមីងចង់មានន័យថា ប្រជាជនកម្ពុជារាប់លាននាក់
មានវាសនាអាក្រក់ដូចៗគ្នាមែនទេ?
ពួកគេទាំងអស់គ្នា?
ខ្ញុំមិនជឿទេ។
គ្មានផ្លូវទេ។

**សុវណ្ណា ~**
ប្រាប់ខ្ញុំមក,
តើឯងចង់បានអ្វី?
ប្រទេសជាតិទទួលយករបត់នេះហើយ។
អំពើប្រល័យពូជសាសន៍ គ្រាន់តែជាគ្រោះមហន្តរាយតែប៉ុណ្ណោះ។
ចូរយើងដឹករណ្តៅ ហើយកប់អតីតកាលឲ្យបាត់ទៅ។
យើងមិនអាចស្តារឡើងវិញពីអ្វីដែលយើងបានបាត់បង់ ឬលុបចោល
គ្រោះមហន្តរាយដែលបានបង្កើតឡើងដោយខ្មែរក្រហមនោះឡើយ។
ចូរបំភ្លេចវាចោលទៅ។

**ភារិទ្ធ ~**
តើពូមីងចង់មានន័យថា នេះគឺអកុតហេតុធម្មជាតិមែនទេ?
នេះមានន័យថា រឿងរ៉ាវអាចកើតឡើងនៅថ្ងៃណាមួយម្តង
ទៀតមែនទេ?
គ្មានផ្លូវទេ!
វាមិនត្រូវបានធ្វើឲ្យវិនាសទាំងស្រុងទេថា អំពើប្រល័យពូជសាសន៍
អាចកើតឡើងវិញបាន។

**សុខលី ~**
វានិយាយត្រូវ។
គ្មានអ្វីដែលកើតឡើងដោយចៃដន្យនោះទេ។
នេះគឺជាអ្វីដែលព្រះពុទ្ធមានពុទ្ធដីកា។

**ស៊ីណា ~**
ត្រូវហើយ។ ព្រះពុទ្ធមានពុទ្ធដីកាថា យើងកើតមក
ជាមួយនឹងអំពើបាប។
អ្វីដែលអាចរាប់បាន គឺអ្វីដែលយើងធ្វើជាមួយអ្នកទាំងនោះ។
ទង្វើពីមុនរបស់យើង នាំយើងទៅរកអ្វីដែលយើងកំពុងធ្វើ
នាពេលបច្ចុប្បន្ន។
ប្រសិនបើ យើងមិនជឿទៅលើទង្វើ និងលទ្ធផលដែលចេញមក
ពីទង្វើទាំងនោះទេ យើងនឹងមិនអាចរស់នៅបានសេចក្តីសុខឡើយ
សម្រាប់ជីវិតយើង។

**សុវណ្ណា ~**
កម្មផល គឺជាចលនាមួយ។ យើងខ្លួនយើងអាចកែច្នៃវាឲ្យមានភាព
ទាក់ទាញ ឬសោះកក្រោះបាន។
ទេ! វាមិនមែនជាការកំណត់វាសនានោះទេ។

អំពើប្រល័យពូជសាសន៍ គឺជាការបង្កើតឡើងដោយមនុស្ស។
របប ប៉ុល ពត គឺជាការបង្កើតឡើងដោយមនុស្ស។
វាគឺជាសង្គ្រាម និងភាពក្រីក្រ ដែលបានធ្វើឲ្យប្រជាជនមានសង្ឃឹម
សម្រាប់អនាគតដ៏រុងរឿងមួយ។
ប៉ុន្តែខ្មែរក្រហមបានធ្វើឲ្យប្រជាជនទាំងនោះកាចសាហាវ
និងប្រព្រឹត្តអំពើឧក្រិដ្ឋ។
យើងត្រូវតែសិក្សាពីចំណុចនេះ។
យើងត្រូវតែយល់ដឹងពីរបៀប និងតួនាទីរបស់សង្គម។
យើងត្រូវចេះកែតម្រូវផលកម្មអាក្រក់ តាមរយៈការស្វែងយល់
របស់យើង។

**ធារី ~**
ការសិក្សាអប់រំ គឺជាដំណោះស្រាយ។

**ភារិទ្ធ ~**
ជនដៃដល់ទាំងនោះ បានទៅសិក្សានៅសាកលវិទ្យាល័យ
ក្នុងប្រទេសបារាំង។
ដើម្បីអ្វី?

**ធារី ~**
ខ្ញុំចង់មានន័យថា ការអប់រំក្មេងៗជំនាន់ក្រោយនៅតាមសាលារៀន
ហើយការអប់រំមនុស្សទាំងឡាយឲ្យបោះបង់ចោលអំពើអាក្រក់
ហើយចាប់យកអំពើល្អ។
នេះគឺជាអ្វីដែលខ្ញុំចង់ប្រាប់ពីការអប់រំ៖ យើងត្រូវតែរៀនសូត្រពី
ប្រវត្តិសាស្ត្រ។
រង្វិលជុំនេះអាចនឹងត្រូវបែកបាក់។
នេះជាមូលហេតុដែលយើងមានតុលាការ។

**ភារិទ្ធ ~**
តើតុលាការបាននាំមកនូវអ្វីខ្លះ?
វាបានចំណាយពេលវេលាជាច្រើនឆ្នាំ និងចំណាយលុយយ៉ាងច្រើន។
មានភាពមិនចុះសម្រុងគ្នាយ៉ាងច្រើននៅក្នុងតុលាការនេះពី
បញ្ហាផ្លូវច្បាប់។ មិនសមហេតុ មិនសមផលសោះ។

**សុវណ្ណា ~**
ជាការល្អហើយដែលមានភាពមិនចុះសម្រុងគ្នានៅក្នុងតុលាការ
ប្រសើរជាជាងការឈ្លោះប្រកែកគ្នានៅតាមភូមិ។
សម្រាប់អ្នកទាំងអស់គ្នា។

**ភារិទ្ធ ~**
មេដឹកនាំជាន់ខ្ពស់ មិនដែលទទួលស្គាល់ពីទង្វើរបស់ខ្លួននោះទេ។

**សុខលី ~**
ប៉ុន្តែអ្នកទាំងនោះត្រូវបានកាត់ទោសដោយតុលាការ ដូច្នេះអ្នកទាំង
នោះត្រូវតែទទួលខុសត្រូវ។

**ភារិទ្ធ ~**
តើភាពទទួលខុសត្រូវមានន័យអ្វីខ្លះ?
ឧក្រិដ្ឋកម្មរបស់អ្នកទាំងនោះ គឺធំធេងណាស់។ ដូច្នេះអ្នកទាំងនោះ
មិនអាចស្នើសុំការលើកលែងទោសបានទេ។

**សុខលី ~**
ជាការល្អហើយដែលវាបានកើតឡើង។ ទោះបីជាលទ្ធផលយ៉ាងណា
ក៏ដោយ ក៏យ៉ាងហោចណាស់អ្វីៗ ត្រូវបានលាតត្រដាងដែរ
សម្រាប់ទាំងអស់គ្នា។

**ភារិទ្ធ ~**
តើពូមីងជឿថា ពូមីងនឹងត្រូវបានផ្តន្ទាទោសទេ
ប្រសិនបើពូមីងធ្វើអំពើអាក្រក់។

**សុខលី ~**
ចាស៎! ខ្ញុំជឿថាអញ្ចឹង។

**ភារិទ្ធ ~**
ដូច្នេះ ខ្មែរក្រហមបានធ្វើរឿងដ៏គួរឲ្យភ័យខ្លាច ហើយអ្នកទាំងនោះ
ប្រហែលជាមិនត្រូវទទួលទោសឡើយ?
អ្នកទាំងនោះ នឹងស្លាប់ដោយស្ងៀមស្ងាត់នៅក្នុងគុកដ៏សុខស្រួល
របស់ខ្លួន។ ឪពុករបស់ខ្ញុំស្អប់អ្នកទាំងនោះណាស់។
គាត់និយាយថា ពួកខ្មែរក្រហមគួរតែត្រូវបានកាប់ដោយកាំបិតឲ្យទៅ
ជាចំណិតតូចៗ រាប់លានចំណិត រហូតដល់ស្លាប់។

**ធារី ~**
គ្មានផ្លូវទេ! ការកាត់ទោសប្រហារជីវិត គឺមិនមានឡើយ!
យើងមិនគួរធ្វើខ្លួនយើងឲ្យទៅជាឧក្រិដ្ឋជនឡើយ។

**ភារិទ្ធ ~**
គាត់បាននិយាយថា អ្នកទាំងនោះគឺជាមនុស្សអាក្រក់។
ពួកគេមិនអាចអភ័យទោសឲ្យបានឡើយ។



**ធារី ~**
ប្រសិនបើយើងនិយាយថាមនុស្សអាក្រក់ គឺមិនអាចលើកលែងឲ្យបាន
យើងគួរផ្តល់អំណាចដែលមិនធ្លាប់មានពីមុនមកដល់អ្នកទាំងនោះ។
យើងផ្តល់អំណាចដល់ពួកគេ ដើម្បីថ្កោលទោសជនរងគ្រោះឲ្យរស់
នៅជារៀងរហូតជាមួយនឹងការឈឺចាប់ដែលមិនអាចព្យាបាលបាន។
យើងផ្តល់នូវពាក្យចុងក្រោយដល់មនុស្សអាក្រក់ទាំងនោះ...

**ភារិទ្ធ ~**
ពុកខ្ញុំពិតជាស្អប់អ្នកទាំងនោះខ្លាំងណាស់!

**សុវណ្ណា ~**
គាត់ត្រូវជាប់គាំងនៅក្នុងគុកនៃការចងចាំដែលឈឺចាប់បំផុត។
ភាពស្អប់ខ្ពើម ត្រូវការការព្យាបាល។ វាគឺជាមេរោគដ៏សាហាវ។
វាគ្រោះថ្នាក់ណាស់ ហើយអាចស្លាប់បាន ប្រសិនបើយើងបណ្តែត
បណ្តោយឲ្យវាកើតឡើង។

**ស៊ីណា ~**
ខ្ញុំគិតថា មេដឹកនាំខ្មែរក្រហមក៏ចាក់សោរខ្លួនឯងជាប់នៅក្នុងគុក
នៃការចងចាំរបស់ពួកគេដែរ។
ពួកគេបានធ្វើឲ្យមានការចងចាំដ៏រន្ធត់មួយ ហើយពួកគេបានស្លាប់
ទៅជាមួយនឹងការចងចាំដ៏រន្ធត់នេះ។

**♪ ចម្រៀង**

*ភាពស្អប់ខ្ពើម និងការសងសឹក មិនដែល*
*ទទួលបានអ្វីមកវិញឡើយ។ វាមិនស្មើនឹងការ*
*ដាក់ពិន្ទុឡើយ។ ភាពស្អប់ខ្ពើម គឺជាជង្រើមដ៏កខ្វក់*
*មួយដែលបំផ្លាញអ្នកស្អប់។*
*ភាពស្អប់ខ្ពើមអ្នកដទៃមានន័យថាស្អប់ខ្ពើមខ្លួនឯង។*
*ប្រសិនបើយើងទាំងអស់គ្នារស់នៅជាមួយនឹងការ*
*សងសឹក ពិភពលោកទាំងមូលនឹងក្លាយជាខ្មៅងងឹត។*
*ភាពស្អប់ខ្ពើម ត្រូវការការព្យាបាល។*

**ភារិទ្ធ ~**
ខ្ញុំយល់ស្រប! ប៉ុន្តែប្រសិនបើយើងមិនស្អប់ទេ យ៉ាងហោចណាស់
យើងក៏អាចមានកំហឹងដែរ។

**ស៊ីណា ~**
ពិតណាស់។
កំហឹង គឺជារឿងធម្មតា។
កំហឹង គឺជាសញ្ញាមួយប្រាប់ថា យើងនៅរស់រានមានជីវិត។
យល់ដឹងពីកំហឹងរបស់យើងនាំយើងឲ្យធ្វើអ្វីមួយដើម្បីផ្លាស់ប្តូរ
អ្វីដែលធ្វើឲ្យយើងខឹង។
ដូច្នេះ កំហឹងជម្រុញយើងឲ្យមានក្តីសង្ឃឹមឆ្ពោះទៅរកអនាគតដ៏
ត្រចះត្រចង់មួយ។ កំហឹង និងការអភ័យទោស អាចរស់នៅ
ជាមួយគ្នានៅក្នុងបេះដូងតែមួយ។

**ភារិទ្ធ ~**
តើពូមីងនិយាយអ្វី? ការអភ័យទោស?
ពូមីងចង់មានន័យថា យើងត្រូវតែអភ័យទោស ហើយបណ្តោយឲ្យ
ទៅតាមដំណើរឬ?
តើរឿងនេះធ្វើយ៉ាងម៉េចទៅរួចទៅ?

**សុវណ្ណា ~**
ការអភ័យទោស គឺជាវិធីតែមួយគត់ដែលយើងត្រូវតែមានភាព
យុត្តិធម៌ដ៏ត្រឹមត្រូវមួយនៅក្នុងពិភពលោកដ៏លម្អៀងរបស់យើង។
ការអភ័យទោស គឺជាភាពរឹងមាំរបស់យើង។
វាគឺជាការធ្វើបដិវត្តន៍ដែលមិនបានគិតទុកជាមុននៃសេចក្តី
ស្រឡាញ់ ប្រឆាំងទៅនឹងការឈឺចាប់ដែលមិនមានយុត្តិធម៌។
(បន្តជាមួយការច្រៀង និងការនិយាយជំនួស)
ការអភ័យទោស បំបាត់ដំណើរជីវិតនៃការចងចាំពីភាព
ឈឺចាប់របស់យើង។
ការអភ័យទោស ជួយសន្សំសំចៃ ការចំណាយកម្លាំងក្នុង
ការខឹង ស្អប់ និងខ្វះខ្វាយគំនិត។
ការអភ័យទោស គឺធ្វើឲ្យយើងមានសេរីភាព។
ការអភ័យទោស គឺមិនត្រូវបានបំភ្លេចឡើយ។
ការអភ័យទោស គឺមិនមែនលុបចោលអតីតកាលដ៏ជូរចត់ឡើយ
ហើយការចងចាំដែលត្រូវបានព្យាបាល គឺមិនមែនជាការចងចាំដែល
ត្រូវបានលុបចោលដែរ ។

# ប្ដូរពី ទន្លេឈាម
## ទៅជាទន្លេនៃការផ្សះផ្សា។ ទន្លេនៃការទទួលខុសត្រូវ។

នៅពេលខ្ញុំអភ័យទោសឲ្យសត្រូវរបស់ខ្ញុំ ខ្ញុំមិនចាំបាច់ក្លាយជាមិត្ត
ជាមួយគាត់នោះទេ។
ការស្អប់ដែលគ្មានទីបញ្ចប់ ធ្វើឲ្យក្លាយទៅជាជនរងគ្រោះនៃអំពើស្អប់
ហើយជាញឹកញាប់កើតមាននៅក្នុងគ្រួសារទាំងមូលរបស់យើង។
យើងមិនត្រូវក្លាយជាទាសករដោយសារតែរឿងរ៉ាវពី
អតីតកាលនោះទេ។

**ភារិទ្ធ ~**

សូមអរគុណ។ ខ្ញុំមានអារម្មណ៍ធូរស្រាលហើយ។
ខ្ញុំរីករាយណាស់ ដែលខ្ញុំបានមករកពូមីង ហើយពូមីងបាន
ឆ្លើយសំណួររបស់ខ្ញុំ។
ខ្ញុំអាចសារភាពនៅចំពោះមុខពូមីងឥឡូវនេះថា ខ្ញុំក្បត់ឪពុកខ្ញុំ ហើយ
បានមកលេងជាមួយអ្នកជិតខាងរបស់ខ្ញុំ។ យើងមានភាពសប្បាយ
រីករាយណាស់ ដែលទង្វើនេះធ្វើឲ្យខ្ញុំសប្បាយចិត្ត។
រហូតមកដល់សព្វថ្ងៃ គាត់នៅតែជាមិត្តល្អបំផុតរបស់ខ្ញុំ។
ឪពុករបស់ខ្ញុំមិនដែលដឹងរឿងនេះទេ។
ឥឡូវ ឪពុករបស់ខ្ញុំបានស្លាប់ហើយ។
សូមអរគុណ។

ពូមីងបានជួយខ្ញុំតាមរយៈពាក្យសម្ដីរបស់ពូមីង។
ប្រហែលជាខ្ញុំមិនមែនជាកូនប្រុសល្អទេ ប៉ុន្តែឥឡូវនេះខ្ញុំមិនសោក
ស្ដាយចំពោះអ្វីដែលខ្ញុំបានធ្វើដោយលួចលាក់នោះឡើយ។
ឥឡូវខ្ញុំអភ័យទោសឲ្យខ្លួនឯង ចំពោះអ្វីដែលខ្ញុំមិនបានប្រាប់
ឪពុកខ្ញុំឲ្យបានដឹង។
គាត់ត្រូវជាប់ជំពាក់នៅក្នុងការឈឺចាប់របស់គាត់។
អ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំមិនអាចព្យាបាលការឈឺចាប់ និងភាពជូរចត់
របស់គាត់បានទេ ព្រោះគាត់មិនអាចចែករំលែកបទពិសោធន៍របស់
គាត់ជាមួយខ្ញុំ។ គាត់ត្រូវជាប់គាំងនៅក្នុងការឈឺចាប់ និងអតីតកាល
របស់គាត់។ ប៉ុន្តែខ្ញុំត្រូវតែកែប្រែជីវិតរបស់ខ្ញុំ។

### ♪ ចម្រៀង

*យើងសោកស្ដាយ។*

*ឆ្លងកាត់របួសស្នាមរបស់យើង។*

*ឥឡូវ៖ ត្រូវតែដើរឆ្ពោះទៅរកអនាគតកាល។*



# សេចក្តីបញ្ចប់

**វុត្ថា ~**
នេះគឺជារឿងទម្លាយភាពស្ងៀមស្ងាត់។

**♪ ចម្រៀង** (វុត្ថា)

*ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។*

*ទន្លេនៃការទទួលខុសត្រូវ។*

*ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។*

*ទន្លេនៃការទទួលខុសត្រូវ។*

**សុខលី ~**
អ្នកបានមើលឃើញផ្ទាល់ភ្នែកពីរឿងរ៉ាវកាលពីសម័យសង្គ្រាម ប៉ុន្តែវាក៏ជារឿងរ៉ាវនៃសេចក្តីស្នេហាដែរ។

**សុវណ្ណា ~**
ក្រោយពីរបបប៉ុល ពត យើងធ្លាប់គិតថា គឺជាការស្អប់ខ្ពើមមួយដែលធ្វើឲ្យយើងរឹងមាំ ស្អប់និងចងកំហឹង។

**ធារី ~**
ប៉ុន្តែឥឡូវនេះ ទើបយើងដឹងថា បើគ្មានសេចក្តីស្រឡាញ់ទេ នោះសតិរបស់យើងអាចនឹងត្រូវបានបំផ្លាញ ហើយព្រលឹងរបស់យើងក៏មិនអាចនៅមានជីវិតដែរ។

**ស៊ីណា ~**
សេចក្តីស្រឡាញ់ទាំងអស់នេះ បានមកពីពុក, ម៉ែ, បង, ប្អូនប្រុស ស្រី, ជីដូន, ជីតា, អ្នកជិតខាង។

**សុខលី ~**
និងក៏ដូចជាសេចក្តីស្រឡាញ់ចំពោះសត្រូវរបស់យើង។



**♪ ចម្រៀង** (វុត្ថា)

*ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។*
*ទន្លេនៃការទទួលខុសត្រូវ។ ប្តូរពីទន្លេឈាម ទៅជាទន្លេនៃការផ្សះផ្សា។*
*ទន្លេនៃការទទួលខុសត្រូវ។*

*និយាយ, និយាយ, និយាយ*

***យើងទាំងអស់គ្នា*** *(នៅពេលដែលកំពុងដើរចូលទៅក្នុងហ្វូងអ្នកទស្សនា ដើម្បីចែកចាយគ្រាប់អង្ករ)៖*

*ភាពឈឺចាប់របស់កម្ពុជា មានទំហំធំធេងណាស់។*

*ពីភាពឈឺចាប់ ទៅជាភាពមេត្តាករុណាដ៏អស្ចារ្យ។*

*សេចក្តីមេត្តាករុណាដ៏អស្ចារ្យ បង្កើតឲ្យមានសន្តិភាព។*

*សន្តិភាព ធ្វើឲ្យមនុស្សមានចិត្តសុខសាន្ត។*

*មនុស្សដែលមានចិត្តសុខសាន្ត បង្កើតឲ្យមានគ្រួសារសុខសាន្ត។*

*គ្រួសារសុខសាន្ត ធ្វើឲ្យសហគមន៍មានសន្តិភាព។*

*សហគមន៍មានសន្តិភាព ធ្វើឲ្យជាតិទាំងមូលមានសន្តិភាព។*

*ជាតិមានសន្តិភាព ធ្វើឲ្យពិភពលោកសុខសាន្ត។*

*សូមឲ្យមនុស្សទាំងអស់រស់នៅក្នុងសុភមង្គល និងសន្តិភាព។*

# ប្រវត្តិនៃល្ខោននិយាយ

(ឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៨)

## ទម្លាយភាពស្ងៀមស្ងាត់

ល្ខោននិយាយ "*ទម្លាយភាពស្ងៀមស្ងាត់*" មានបំណងបង្កើត និងនាំយកទម្រង់ថ្មីនៃល្ខោននិយាយដ៏ជោគជ័យមួយនេះទៅសម្តែងជាសាធារណៈ ផ្តែកលើសក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងចូលរួមចំណែកក្នុងការពិភាក្សាពីមួយជំនាន់ទៅកាន់មួយជំនាន់ទៀត ក៏ដូចជារវាងអតីតអ្នកគាំទ្រខ្មែរក្រហម និងជនរងគ្រោះនៃរបបខ្មែរក្រហមអំពីឥទ្ធិពលនៃអំពើប្រល័យពូជសាសន៍។ ចាប់តាំងពីការកកើតល្ខោននេះមក លទ្ធផលប្រកបដោយការមិនពេញចិត្តនៃសាលាក្តីខ្មែរក្រហមបានជះឥទ្ធិពលលើជំនឿ និងការទុកចិត្តរបស់ប្រជាជនចំពោះប្រព័ន្ធយុត្តិធម៌របស់ប្រទេសខ្លួន។ ដំណើរការនៃការផ្សះផ្សាទាមទារឲ្យមានការឆ្លើយតបទៅនឹងសំណួរស្តីពីកម្មផល និងការទទួលខុសត្រូវ។ ល្ខោននិយាយ *រឿងទម្លាយភាពស្ងៀមស្ងាត់* មានរួមបញ្ចូលធាតុផ្សំដែលអាចជាឧបករណ៍ដ៏មានប្រសិទ្ធិភាពក្នុងការតតាំងប្រកបដោយសេចក្តីទៀងត្រង់បែបសិល្បៈទៅនឹងដំណាក់កាលចុងក្រោយដ៏សំខាន់របស់សាលាក្តីខ្មែរក្រហម។ អ្នកនិពន្ធ និងជាអ្នកដឹកនាំ អាន់ម៉ារី ព្រីនស៍ ប្តេជ្ញាតែងនិពន្ធឈុតឆាកមួយចំនួនសារជាថ្មី និងបន្ថែមឈុតឆាកថ្មីមួយដើម្បីតតាំងនឹងឥទ្ធិពលពីភាពរង្គោះរង្គើរនៃប្រព័ន្ធយុត្តិធម៌ដែលមិនជោគជ័យ។

### ដំណាក់កាលទី១

ការកកើតនៃគម្រោងនេះចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ២០០៨ នៅពេលដែលអ្នកនិពន្ធ និងអ្នកសសេរទំនុកល្ខោន អាន់ម៉ារី ព្រីនស៍ និង ណាន វ៉ាន់ហួត បានធ្វើការស្រាវជ្រាវអំពីដំណើរការនៃការផ្សះផ្សានៅក្នុងប្រទេសកម្ពុជាតាមរយៈការអញ្ជើញរបស់អង្គការអម្រឹតសិល្បៈ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួយសម្របសម្រួលការចុះសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់ដោយអនុញ្ញាតឲ្យមានការប្រើប្រាស់សក្ខីកម្ម និងរៀបចំការបញ្ចាំងខ្សែវីដេអូ ក៏ដូចជាខ្សែភាពយន្តប្រវត្តិសាស្ត្រនានា។

ល្ខោននេះធ្វើឲ្យអ្នករស់រានមានជីវិត ទាំងជនរងគ្រោះ និងជនដៃដល់មានភាពរស់រវើក តាមរយៈការរៀបរាប់ក្នុងរឿងចំនួន ៧។ ស្ថានភាពជីវិតប្រចាំថ្ងៃចំនួន ៧ បង្ហាញអំពីភាពឈឺចាប់ និងភាពមិនចេះទ្រុឌទ្រោមក្នុងការប្រឈមទៅនឹងបទពិសោធន៍នានា ស្ថិតក្រោមរបបខ្មែរក្រហម។ តួអង្គសម្តែងបង្ហាញនូវអារម្មណ៍សោកស្តាយ ភ័យខ្លាច ទុក្ខព្រួយ ភ័ន្តច្រឡំ និងក្តីសង្ឃឹម ខណៈពេលដែលខ្លួនព្យាយាមប្រឈមនឹងរឿងហេតុទាំងនោះ និងផ្សះផ្សាជាមួយនឹងអតីតកាលដែលប្រកបទៅដោយបញ្ហា។

"*ទម្លាយភាពស្ងៀមស្ងាត់*" ត្រូវបានសម្ពោធនៅក្នុងមជ្ឈមណ្ឌលពិព័រណ៍ជាតិក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងសប្តាហ៍តែមួយជាមួយនឹងការចាប់ផ្តើមសវនាការជាផ្លូវការរបស់សាលាក្តីខ្មែរក្រហម។ ភ្លាមៗ បន្ទាប់ពីការសម្ពោធស្នាដៃនេះ ការសម្តែងល្ខោននេះបានបន្តជាសាធារណៈក្នុងខេត្តមួយចំនួននៅប៉ែកខាងត្បូងប្រទេសកម្ពុជា។ គោលបំណងរបស់យើង គឺដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់វ័យទទួលបានប្រយោជន៍ពីស្នាដៃនេះ តាមរយៈការប្រឈមចំពោះបញ្ហានានា ទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេង ដែលបានកើតមានឡើងតាមរយៈមជ្ឈដ្ឋានប្រកបដោយសុវត្ថិភាព ភាពច្នៃប្រឌិត និងសេចក្តីភ្ញាក់រឭក។ ប្រជាជនកម្ពុជាទទួលបានឱកាសក្នុងការលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួននៅមុន និងក្រោយពេលល្ខោនចុះទៅសម្តែង ដែលមានការសម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

សកម្មភាពនេះ ក៏ផ្តល់ជាជំនួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកវិធីសាស្ត្រ សម្រាប់បំពេញដំណើរការនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្តក៏ដូចជាវិធីសាស្ត្រដទៃទៀតក្នុងការបន្តដំណើរឆ្ពោះទៅមុខទៀត។ តាមរយៈវិធីសាស្ត្រទាំងនេះ និងវិធីសាស្ត្រដទៃទៀត ការសម្តែងជាសាធារណៈតាមបណ្តាខេត្តលើកដំបូងបង្អស់ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យយ៉ាងធំធេង។ស្នាដៃនេះត្រូវបានសម្តែងជូនដល់ប្រជាជនកម្ពុជាប្រមាណជាង៧ពាន់នាក់នៅក្នុងទីតាំងផ្សេងៗគ្នា។

### ដំណាក់កាលទី២

ឆ្លើយតបទៅនឹងប្រតិកម្មដ៏វិជ្ជមាន ការសម្តែងជាសាធារណៈត្រូវបានរៀបចំឡើងនៅក្នុងខេត្តកំពត និងខេត្តតាកែវ នៅក្នុង ខែកុម្ភៈ ឆ្នាំ២០១០។ជាថ្មីម្តងទៀត ប្រជាជនកម្ពុជារាប់ពាន់នាក់បានចូលទស្សនាការសម្តែងនេះ។ប្រជាជនជាច្រើនបានចូលរួមនៅក្នុងកិច្ចពិភាក្សានៅក្រោយការសម្តែងបានបញ្ចប់ដោយបានរៀបរាប់ពីទុក្ខវេទនាការជ្រើសរើសខុសឬទង្វើមិនគប្បីរបស់ខ្លួននៅក្នុងអំឡុងពេលនៃរបប ប៉ុល ពត ជាដើម។ ចំណែកឯក្មេងៗជំនាន់ក្រោយបានលើកឡើងជាសំណួរផ្សេងៗមកកាន់យើងខ្ញុំ។

ការសម្តែងខាងលើបានប្រព្រឹត្តទៅស្របពេលជាមួយនឹងការចាប់ផ្តើមសំណុំរឿង០០២ ដែលគឺជាសវនាការលើកទីពីររបស់សាលាក្តីខ្មែរក្រហមពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត។ ដោយសារសារៈសំខាន់នៃសំណុំរឿង០០២ និងការយល់ឃើញអំពីតម្រូវការក្នុងការបញ្ជ្រាបទៅកាន់ប្រជាជនកម្ពុជាដែលរស់នៅបែកខ្ញែកគ្នា (និងប្រជាជនស្ថិតនៅតំបន់ដាច់ស្រយាល) មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើឲ្យ អាន់ម៉ារី ព្រីនស៍ សរសេរជាឯកសារ និងថតល្ខោននេះជាសម្លេងដើម្បីចាក់ផ្សាយតាមវិទ្យុ។ ការផ្សាយល្ខោននិយាយ "*ទម្លាយភាពស្ងៀមស្ងាត់*" នៅតាមវិទ្យុជារៀងរាល់ថ្ងៃបានចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ២០១០ និងបន្តរហូតមកដល់សព្វថ្ងៃនេះ។

### ទម្លាយភាពស្ងៀមស្ងាត់ និង សាលាក្តីខ្មែរក្រហម

ល្ខោននិយាយរឿង "*ទម្លាយភាពស្ងៀមស្ងាត់*" ទទួលបានផលប្រយោជន៍ព្រមទាំងចូលរួមចំណែកដល់ភាពចាំបាច់ដ៏វិសេសវិសាលក្នុងការបញ្ចប់ភាពស្ងៀមស្ងាត់ ស្របពេលដែលល្ខោននេះក្លាយជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សាដើម្បីចាប់ផ្តើមកាផ្សះផ្សា។ ទោះបីជាបញ្ហាទាក់ទងនឹងសាលាក្តីខ្មែរក្រហមពុំត្រូវបានលើកឡើងនៅក្នុងល្ខោននេះក្តី ក៏កម្មវិធីនៅមុនពេលនិងក្រោយពេលសម្តែងមានរួមបញ្ចូលពីការពិភាក្សា ដោយផ្អែកលើឥទ្ធិពលនៃសាលាក្តីខ្មែរក្រហម ដែលចំណាយថវិកាអស់ជាច្រើនរយលានដុល្លារសហរដ្ឋអាមេរិក ដោយបានលើកឡើងអំពីតួនាទីរបស់សាលាក្តីខ្មែរក្រហមក្នុងការស្តារជំនឿទុកចិត្តចំពោះប្រព័ន្ធច្បាប់និងយុត្តិធម៌។ មេដឹកនាំខ្មែរក្រហមចំនួន ៥រូប ត្រូវបាននាំមកកាន់សវនាការដែលសកម្មភាពនេះបានលើកទឹកចិត្តឲ្យប្រជាជនមានការអត់ឱន ចំពោះបុគ្គលដែលទទួលខុសត្រូវថ្នាក់មូលដ្ឋានទាំងឡាយ។

ថ្វីបើល្ខោននិយាយរឿង "*ទម្លាយភាពស្ងៀមស្ងាត់*" ពុំមែនជាការតាក់តែងនិពន្ធ ដើម្បីស្នើសុំការលើកលែងទោសក្តីក៏ល្ខោននេះត្រូវបានដាក់បញ្ចូលសកម្មភាពរបស់អ្នកដែលប្រព្រឹត្តខុសឆ្គងទៅក្នុងបរិបទមួយ និងបង្ហាញអំពីដំណើរការនិងមូលហេតុដែលកុមារកុមារី និងយុវជនវ័យក្មេងៗ សម្រេចជ្រើសរើសគាំទ្រខ្មែរក្រហម និងការដែលមិនអាចបកត្រឡប់ក្រោយបាននាពេលបន្ទាប់។ ទន្ទឹមនឹងនេះដែរ ល្ខោននេះក៏បានលើកឡើងអំពីពុទ្ធដីកាទូន្មានរបស់ព្រះពុទ្ធ។ តាមរយៈការស្នើសុំនៅក្នុងដំណាក់កាលថ្មីនៅក្នុង ខែកក្កដា ឆ្នាំ២០១២ យើងទទួលស្គាល់ថា សាលាក្តីខ្មែរក្រហមអាចនឹងបញ្ចប់ទៅជាមួយនឹងលទ្ធផលមិនសមប្រកបក្នុងកម្រិតណាមួយ ដោយសារតែមេដឹកនាំខ្មែរក្រហមភាគច្រើនមានវ័យចាស់ ឬមានជំងឺដែលពិបាកក្នុងការចូលរួមក្នុងសវនាការបាន។

មានការពិបាកណាស់ក្នុងការយកឈ្នះលើអារម្មណ៍នៃភាពអយុត្តិធម៌ ដែលប្រជាជនកម្ពុជាជាច្រើនកំពុងតែមាននៅពេលនេះ និងក្នុងការធ្វើឲ្យមានតុល្យភាពជាមួយនឹងជំនឿរបស់អ្នកទាំងនោះលើកម្មផល។ តើយើងអាចជឿបានទេថា អ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះជីវិតដែលបានបាត់បង់ជាងពីរលាននាក់នឹងទទួលបានផលកម្ម ចំពោះទង្វើរបស់ខ្លួននៅជាតិខាងមុខដែរឬទេ? តើអំពើប្រល័យពូជសាសន៍ និងលទ្ធផលបន្ទាប់អាចបង្ហាញអំពីកម្មផលរបស់អ្នកប្រព្រឹត្តដែរឬយ៉ាងណា? តើយើងអាចអត់ឱនទោសដល់អ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅ ទោះបីជាអ្នកទាំងនេះមិនទទួលទោសនៅមុនពេលដែលខ្លួនស្លាប់ដែរឬទេ? តើយើងអាចអត់ឱនដល់ផលកម្មអាក្រក់បានដែរឬទេ? បន្ទាប់ពីការសម្តែងនៅឃុំទានក្នុង ខេត្តកណ្តាលរួចមក អាចារ្យវ័យចំណាស់ម្នាក់ក្នុងចំណោមអ្នកផ្តល់បទសម្ភាសដទៃទៀត ក្នុងអំឡុងពេលនៃទស្សនកិច្ចស្រាវជ្រាវបានចាប់យកឧត្បោសនស័ព្ទ ហើយបាននិយាយដ៏មានអត្ថន័យ ព្រមទាំងបញ្ចប់ដោយសំណួរបើកមួយទៅកាន់សហគមន៍របស់គាត់ថា៖ តើអ្នកគួរលើកលែងទោសឲ្យ ប៉ុល ពត ដែរឬទេ?

## ដំណាក់កាលទី៣៖ ដំហានចុងក្រោយ

សាលាក្ដីខ្មែរក្រហម មិនទទួលបានជោគជ័យទាំងស្រុងចំពោះការផ្ដល់ភាពយុត្តិធម៌។ ផ្ទុយទៅវិញ សាលាក្ដីខ្មែរក្រហមនេះបានបង្កើតភាពមន្ទិលសង្ស័យ។ សំណួរថ្មីៗជាច្រើនត្រូវបានលើកឡើង និងតម្រូវឲ្យធ្វើការឆ្លើយតប ដើម្បីអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្ដើមស្ដារសង្គមដ៏ខ្ទេចខ្ទាំនេះឡើងវិញ។ ប្រជាជនកម្ពុជាអាចនឹងត្រូវសម្រេចចិត្តថា តើដំណើរការនេះនឹងមានប្រយោជន៍សម្រាប់ប្រទេសជាតិ សម្រាប់ខ្លួនឯងផ្ទាល់ និងសម្រាប់ការអត់ឱនដល់ជនដៃដល់ ដែលពុំធ្លាប់សារភាពនូវការស្នើសុំការលើកលែងទោស ឬក៏ត្រូវដាក់ទោស។ អ្នកនិពន្ធ ពិតជាចង់សាកល្បងរាល់បញ្ហាចោទឡើងនានាក្នុងការបង្កើតរឿង *"ទម្លាយភាពស្ងៀមស្ងាត់"* ក្នុងទម្រង់ថ្មីដែលធ្វើការឆ្លើយតបច្បាស់លាស់ជាងមុនទៅកាន់សំណួរស្ដីពីកម្មផល និងសាលាក្ដីខ្មែរក្រហម។

គម្រោងនេះ ដូចគ្នានឹងគម្រោងជាច្រើនទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដែលដើរតួនាទីជាកម្មវិធីស្ដីពីការពិត និងការផ្សះផ្សាក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។តាមរយៈការធ្វើឲ្យប្រសើរឡើងនូវល្ខោននិយាយដើម្បីឆ្លើយតបទៅនឹងសំណួរនានា ដែលបានលើកឡើងអំពីសាលាក្ដីខ្មែរក្រហម ក្នុងនោះរួមមានបញ្ហាចម្បងស្ដីពីកម្មផល យើងមានបំណងចូលរួមជាមួយទស្សនិកជនទាំងឡាយក្នុងប្រទេសកម្ពុជាក្នុងការស្វែងរកចម្លើយសម្រាប់សំណួរដ៏ពិបាក ដែលបានលើកឡើងអំពីគុណវិបត្តិនៃសាលាក្ដីខ្មែរក្រហម និងត្រិះរិះពិចារណាអំពីបែបផែនផ្សេងៗ ដែលសាលាក្ដីខ្មែរក្រហមនេះអាចចូលរួមចំណែកក្នុងដំណើរការនៃការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សានៅកម្ពុជា។





# ទម្លាយភាព ស្ងៀមស្ងាត់

## ល្ខោននិយាយ "ទម្លាយភាពស្ងៀមស្ងាត់"
## កម្មវិធីសម្រាប់ឆ្នាំ២០១៩

កម្មវិធីសម្ដែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» នឹងត្រូវធ្វើឡើងនៅក្នុងទីតាំងចំនួន៥ ដូចខាងក្រោម៖

**រាជធានីភ្នំពេញ**
ថ្ងៃទី១០-១១ ខែមករា ឆ្នាំ២០១៩

**ខេត្តតាកែវ**
ថ្ងៃទី១១-១៤ ខែកុម្ភៈ ឆ្នាំ២០១៩

**ខេត្តកំពង់ចាម**
ថ្ងៃទី៤-៧ ខែមិនា ឆ្នាំ២០១៩

**ខេត្តព្រៃវែង**
ថ្ងៃទី១-៤ ខែឧសភា ឆ្នាំ២០១៩

**ខេត្តបាត់ដំបង**
ថ្ងៃទី២១-២៤ ខែឧសភា ឆ្នាំ២០១៩

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីសម្ដែងទាំង ៥កន្លែង ខាងលើសូមទាក់ទង៖
មីន សាណាស់ និង ស៊ាង ចិន្ដា
អ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួល
កម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា/
វិចិត្រសាលសហសម័យវិទ្យាស្ថានស្លឹករឹត
ទូរសព្ទ៖ +៨៥៥ (០)១០ ៨៤៨ ៤៤៤ ឬ +៨៥៥ (០)១២ ៦៦៣ ៦១១
អ៊ីមែល៖ truthsanas@dccam.org or truthchenda.s@dccam.org

AMRITA PERFORMING ARTS
អម្រឹតាសិល្បៈ







**៧ មករា ១៩៧៩ - ៧ មករា ២០១៩**

# ៤០ឆ្នាំ

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត
ការផ្សះផ្សានៅកម្ពុជាស្ថិតក្នុងស្ថានភាពងាយប្រេះស្រាំនៅឡើយ។

## មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាចូលជាធរមាន ដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការកោតសរសើរ និងមេដាយជាច្រើនសម្រាប់កិច្ចការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ក្នុងឆ្នាំ២០០៧ប៉ុណ្ណោះមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពានរង្វាន់សិទ្ធិមនុស្ស ជូឌិត លី ស្ត្រូណាច់ ពីមជ្ឈមណ្ឌលសម្រាប់ការទទួលខុសត្រូវនិងយុត្តិធម៌។ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ក្នុងការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាអ្នកឈ្នះពានរង្វាន់ រ៉ាម៉ុន ម៉ាក់សៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី សម្រាប់ការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រ សម្រាប់ការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។

# ទម្លាយភាពស្ងៀមស្ងាត់

## ការសម្តែងថ្មីរបស់កម្ពុជា

និពន្ធដោយ អាន់ម៉ារី ព្រីនស៍

សិល្បៈមិនត្រឹមតែជាផ្នែកមួយនៃការកំសាន្ត និងការបំផុសគំនិតតែប៉ុណ្ណោះទេ ប៉ុន្តែសិល្បៈក៏ជាផ្នែកមួយនៃការបង្ហាញឲ្យឃើញពីជម្រៅទុក្ខសោករបស់មនុស្ស ភាពភ័យរន្ធត់ និងអំពើអាក្រក់ដែរ។ ក្នុងបរិបទទាំងពីរនេះ សិល្បៈអាចដើរតួជាផ្នែកមួយដ៏មានសារៈសំខាន់សម្រាប់ការអប់រំ។ ការទម្លាយភាពស្ងៀមស្ងាត់ គឺជាកិច្ចការសិល្បៈមួយដែលព្យាយាមរួមបញ្ចូលជាតុផ្សំនៃវត្ថុដ៏អស្ចារ្យនៅក្នុងក្បាច់រាំនៅក្នុងបរិបទរឿងរ៉ាវពីអំពើប្រល័យពូជសាសន៍ និងភាពរន្ធត់។ ដោយសារតែតម្លៃនៃការអប់រំ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលការសម្តែងតួពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩ នៅក្នុងកម្មវិធីសិក្សា និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនរបស់ខ្លួន។ គ្រប់ទម្រង់ទាំងអស់ សិល្បៈមិនត្រឹមតែជាវិធីដ៏ល្អបំផុតក្នុងការចងចាំពីអតីតកាលតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលទាំងការចងចាំតាមរបៀបផ្សេងៗគ្នាសម្រាប់ថ្នាក់រៀន និងសាធារណៈ។ កម្មវិធីនេះទទួលបានការឧបត្ថម្ភ និងគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងសម្ព័ន្ធអន្តរជាតិនៃទីតាំងមនសិការ។

ចេញផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ២០១៨។

ស៊ុយអែត Sverige

USAID FROM THE AMERICAN PEOPLE

International Coalition of SITES of CONSCIENCE
Past to Present, Memory to Action